ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-May-2015, 15:40
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២៧៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធួ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ
លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*
កញ្ញា ជា ស៊ីវហ័ង
កញ្ញា ម៉ារី-ជេនី សាដាទិ
*(Ms. Marie-Jeannes SARDACHTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង លាង
លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ល សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ខឹម បឿន (2-TCW-979) | ខ្មែរ |
| លោក ម៉ម រិទ្ធា (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ខឹម ចឿន ហៅ យាយចឿន** (2-TCW-979)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ............................................................ទំព័រ ២

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី.......................................................................ទំព័រ ១១

សួរដោយលោក គង់ សំអុន ផ្តើមពី ........................................................................ទំព័រ ៤៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ខឹម បឿន តាមរយៈប្រព័ន្ធសោតទស្សន៍។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ រាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីមានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ លោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតបោះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោកស្រី ខឹម បឿន តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបាត់ដំបង។ តាមការបញ្ជាក់ពីផ្នែកបច្ចេកទេសសោតទស្សន៍បានជូនដំណឹងថា ការរៀបចំផ្នែកបច្ចេកទេសសម្រាប់ការស្តាប់សក្ខីកម្មនៅពេលនេះបានរៀបចំរួចរាល់ហើយ។ រីឯសាក្សី និងមេធាវីប្រឹក្សាលោក ម៉ម រិទ្ធា បានត្រៀមខ្លួនរួចជាស្រាចសម្រាប់ការផ្តល់សក្ខីកម្មនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៣:២១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបឋមនេះ អង្គជំនុំជម្រះសម្រេចលើស្នើសុំរបស់ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខ ឲ្យមានប្រសិទ្ធភាព ខ្លួនសូមលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយ

ផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥។

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះទេ ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៤:១៤]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់ នួន ជា មានជំងឺឆ្អឹងចង្កេះ និងបានផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសម្រាប់ថ្ងៃនេះ។

បាទ មុននឹងផ្ដល់វេទិកាជូនទៅភាគីមេធាវីការពារក្ដី អង្គជំនុំជម្រះសួរទៅអស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីចង់សួរទៅសាក្សី ខឹម បឿន ដែរឬទេ? ហើយដំបូង -- បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**សៈ** ជម្រាបសួរលោកស្រីសាក្សី។ លោកស្រីស្ដាប់ឮខ្ញុំនិយាយទេ?

**លោកស្រី ខឹម ឿន៖**

**ឆ៖** ចាស ឮ។ ចាសជម្រាបសួរ។

**ស៖** លោកស្រី ខ្ញុំមានសំណួរបន្តិចបន្តួចទេ ដើម្បីសួរបន្តពីសំណួរដែលបានសួររួចមកហើយ។ ជាដំបូងខ្ញុំចង់ត្រឡប់មកនិយាយអំពីកាលបរិច្ឆេទ ដែលលោកស្រីត្រូវបានគេតែងតាំងជាមេឃុំជាងទង។ តើលោកស្រីអាចជម្រាបអង្គជំនុំជម្រះបានច្បាស់ទេថា នៅពេលណាដែរដែលលោកស្រីត្រូវបានគេតែងតាំងជាមេឃុំជាងទងនេះ?

**ឆ៖** ចាស សូមជម្រាបលោកប្រធាន ការតែងតាំងខ្ញុំមិនចាំពេលវេលា និងថ្ងៃខែទេ តែខ្ញុំចាំក្នុងឆ្នាំ គឺចុងឆ្នាំ៧៣។ ឯការតែងតាំងមិនមានជាកម្មវិធីអីទេ គេគ្រាន់តែប្រាប់ឲ្យធ្វើតែប៉ុណ្ណោះ។

**ស៖** តើលោកស្រីចាំឈ្មោះអ្នកដែលជាមេឃុំជាងទងហ្នឹងមុនលោកស្រីទេ?

**ឆ៖** ចាស ខ្ញុំមិនសូវចាំដែរនេះ។ មុនហ្នឹងមានឈ្មោះ--

[០៩:០៧:៤៣]

**ស៖** សៅ វ៉ាន់ ហៅ សៅ ពត លោកស្រីស្គាល់ឈ្មោះហ្នឹងទេ?

**ឆ៖** ចាស អត់ច្បាស់ សុំម្តងទៀត។

**ស៖** សូមអភ័យទោស ពីព្រោះថាខ្ញុំនិយាយឈ្មោះប្រហែលមិនត្រូវទេ។ ឈ្មោះដែលខ្ញុំចង់សួរលោកស្រីនោះគឺ សៅ វ៉ាន់ ហៅ សៅ ពត។

**ឆ៖** ចាស។

**ស៖** តើឈ្មោះហ្នឹងគាត់មានទំនួលខុសត្រូវអ្វីដែរ?

**ឆ៖** ពីមុនខ្ញុំមិនបានដឹងច្បាស់ដែរ ដឹងថាគាត់ធ្វើពីមុនខ្ញុំគឺគាត់ អ្នកទទួលនៅក្នុងឃុំហ្នឹង។ មិនដឹងតំណែងជាអីដែរ។

**ស៖** គាត់ទទួលខុសត្រូវក្នុងពេលជាមួយគ្នានឹងលោកស្រី ឬក៏យ៉ាងម៉េច? ហើយគាត់កាន់ហ្នឹងរហូតទៅដល់ពេលណាដែរ?

**ឆ៖** គាត់កាន់ជាមួយខ្ញុំ មិនដឹងជាដល់ពេលណាខ្ញុំមិនចាំដែរ។ ប៉ុន្តែបាននៅជាមួយគ្នាបានពេលយូរដែរ។

**ស៖** នៅក្នុងកំណត់ហេតុរបស់លោកស្រី លោកស្រីនិយាយពីឈ្មោះ សំ ប៊ិត តើលោកស្រីអាចជម្រាបអង្គជំនុំជម្រះបានទេថា សំ ប៊ិត នេះគាត់មានតួនាទីអ្វីដែរ?

**ឆ៖** ចាស សំ ប៊ិត ហ្នឹងខ្ញុំស្គាល់គាត់ក៏មិនច្បាស់លាស់ដែរ។ ប៉ុន្តែកាលពីមុនឃើញគាត់មកធ្វើការក្នុងតំបន់តាកែវហ្នឹង ហើយក្រោយមកខ្ញុំអត់បានដឹង។

[០៩:១០:៥៦]

**ស៖** តើលោកស្រីធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំដែលមាន សំ ប៊ិត ជាអ្នកដឹកនាំទេ? ប្រសិនបើធ្លាប់នោះ ថាតើនៅពេលប្រជុំទាំងនោះ គេពិភាក្សាអំពីរឿងអ្វីដែរ?

**ឆ៖** ខ្ញុំអត់ដែលបានទៅចូលរួមប្រជុំទេ។

**ស៖** កាលពីម្សិលមិញគេនិយាយអំពីឈ្មោះ ដាំ ប្រាប់លោកស្រី។ ដាំ នេះធ្វើការនៅមន្ទីរស្រុក លោកស្រីឆ្លើយថា លោកស្រីចាំឈ្មោះគាត់។ តើលោកស្រីអាចបញ្ជាក់អំពីតួនាទីរបស់គាត់នៅមន្ទីរស្រុកហ្នឹងបានទេ ថាគាត់ធ្វើអ្វីដែរនៅទីនុំង?

**ឆ៖** ដាំ អត់មានធ្វើការនៅមន្ទីរស្រុកទេ។ ខ្ញុំនឹកមិនទាន់ឃើញ។

**ស៖** អ៊ីចឹងតើគាត់មានមុខងារអ្វីដែរ បើសិនជាគាត់មិនធ្វើការនៅមន្ទីរស្រុកទេ គាត់ធ្វើការនៅឯណាដែរ?

**ឆ៖** ដាំ គឺតាមខ្ញុំដឹង គាត់ធ្វើការនៅកន្លែងក្រាំងតាចាន់។

**ស៖** តើលោកស្រីធ្លាប់ជជែកគ្នាជាមួយ ដាំ ទេ? ហើយធ្លាប់ជួបគាត់ទេ?

**ឆ៖** គាត់ទៅធ្វើការស្រុក ខ្ញុំអត់ដែលបានជួបទេ ទៅធ្វើការនៅមន្ទីរហ្នឹង។

[០៩:១៣:០១]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅសហព្រះរាជអាជ្ញារងអន្តរជាតិ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអភ័យទោសលោកប្រធាន ចំពោះការផ្តាច់នេះ។ ខ្ញុំគិតថា ប្រហែលជាមានការច្រឡំគ្នាពាក់ព័ន្ធនឹងការបញ្ចេញសំឡេង ពីព្រោះថាយើងនិយាយអំពី ដាំ ហើយបើលោកចៅក្រមប្រហែលជាគាត់សំដៅទៅលើឈ្មោះ ដន ទេ។ អ៊ីចឹងប្រហែលជាអាចមានការច្រឡំគ្នារវាង ដាំ និង ដន នេះ។ អ៊ីចឹងខ្ញុំសូមឲ្យមានការបញ្ជាក់ពីឈ្មោះនេះឡើងវិញ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកស្រីសាក្សី លោកស្រីស្តាប់សម្តីរបស់សហព្រះរាជអាជ្ញាអម្បាញ់មិញនេះទេ

ប្រហែលជាមានមនុស្សពីរនាក់ផ្សេងគ្នា។ ដាំ ដែលជាអ្នកធ្វើការនៅក្រាំងតាចាន់ និង ដន ដែលធ្វើការនៅមន្ទីរស្រុក។ តើលោកស្រីចាំពីឈ្មោះ ដន ដែលធ្វើការនៅមន្ទីរស្រុកទេ?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ដន ចាស សូមបញ្ជាក់ឈ្មោះ ដន។ ដន--

**ស៖** តើ ដន ធ្វើការនៅមន្ទីរស្រុកហ្នឹងរហូតដល់ពេលណាដែរ?

**ឆ៖** ដន ធ្វើការនៅមន្ទីរស្រុករហូតដល់ ខ្ញុំមិនចាំដែរ ភ្លេចៗបាត់ហើយ ប៉ុន្តែធ្វើវែង គាត់ធ្វើយូរ តែខ្ញុំអត់បានចាំទេ។

**ស៖** ហើយក្រោយមកហ្នឹង ដន ហ្នឹងគាត់ទៅណាទៀត?

**ឆ៖** ខ្ញុំអត់ដឹងដែរ ក្រោយមកដឹងគាត់ទៅណា ព្រោះខ្ញុំអត់នៅក្នុងមន្ទីរស្រុកផង។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពី ដាំ ដែលធ្វើការនៅក្រាំងតាចាន់។ តើ ដាំ នេះ គាត់ធ្វើការនៅក្រាំងតាចាន់រហូត ឬក៏គាត់មានពេលណាមួយនោះ គាត់ឈប់ធ្វើការនៅក្រាំងតាចាន់?

**ឆ៖** ខ្ញុំអត់បានចាំដែរ ព្រោះគាត់អត់នៅក្នុងឃុំកន្លែងដែលខ្ញុំធ្វើការផង។

**ស៖** តើលោកស្រីដឹងទេថា ក្រោយមក ដាំ នេះត្រូវបានគេចាប់ឃុំនៅក្រាំងតាចាន់?

**ឆ៖** ខ្ញុំអត់បានដឹងផង។

**ស៖** តើលោកស្រីចាំទេ ថាគេបានបង្ហាញឯកសារមួយជូនលោកស្រី គឺឯកសារ D157.64 លោកមេធាវីប្រឹក្សា លោកអាចជួយរកឯកសារហ្នឹងជូនទៅសាក្សីផង។ តើលោករកឯកសារហ្នឹងឃើញទេ គឺ D157.64។

[០៩:១៧:៥៧]

**លោក ម៉ម រិទ្ធា៖**

សូមគោរពលោកចៅក្រម កំពុងតែស្វែងរកព្រោះគ្រាន់តែឃើញនៅក្នុង *ខន់ថេន* វា តែឯកសារវាច្រើន កំពុងតែរែកមើលបន្តិច។ បាទ ឃើញហើយ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែរ៍៖**

**ស៖** សម្រាប់ជាកំណត់ហេតុសវនាការគឺERNជាភាសាខ្មែរ 00270974 ទៅដល់ 75, ERN ជាភាសាបារាំង 00789272 ទៅដល់ 73, ERN ជាភាសាអង់គ្លេស 00363655។ លោកស្រីសាក្សី តើលោកស្រីមើលឃើញឯកសារហ្នឹងហើយឬនៅ?

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស កំពុងមើល។

**ស៖** តើពេលដែលមើលឯកសារហ្នឹងហើយ ធ្វើឱ្យលោកស្រីនឹកឃើញអ្វីទេ?

**ឆ៖** ចាស ខ្ញុំឃើញឯកសារនេះ ប៉ុន្តែខ្ញុំនឹកមិនឃើញ ព្រោះពេលនោះខ្ញុំនៅក្នុងឃុំនៅឡើយ ខ្ញុំមិនទាន់មកនៅក្នុងស្រុកទេ។

**ស៖** លោកស្រីមានមើលឃើញហត្ថលេខានៅខាងក្រោមទំព័រចុងក្រោយទេ?

**ឆ៖** ចាស ឃើញ។

**ស៖** លោកស្រីស្គាល់ហត្ថលេខាហ្នឹងទេ?

**ឆ៖** ចាស ហត្ថលេខាគឺឈ្មោះខ្ញុំ តែខ្ញុំនឹកមិនឃើញ។

**ស៖** មានការសរសេរនៅជិតហត្ថលេខារបស់លោកស្រីហ្នឹងថា "ចម្លងចេញពីសមមិត្ត ហួត គណៈ៤ -- គណៈកង៤"។ អ៊ីចឹង ខ្ញុំចង់ដឹងថា ឈ្មោះ ហួត ដែលជាគណៈកង៤ហ្នឹង ជាអ្នកណាគេដែរ?

[០៩:២២:១១]

**ឆ៖** ចាស មិនមែនឈ្មោះ ហួត ទេ គឺឈ្មោះ ហួរ ដែលនៅក្នុងកង៤ហ្នឹង មិនមែន ហួត ទេ ហួរ។ គាត់កាលនោះគាត់ជាប្រធានកង។ គាត់ជាមេកងនៅតាមភូមិ។

**ស៖** កង៤ហ្នឹងមានមុខងារអ្វីដែរ ជាកងឈ្លប ឬក៏ជាកងអ្វី?

**ឆ៖** កង៤ហ្នឹង ខ្ញុំចង់និយាយថា គេរៀបចំកងហ្នឹងកងបុរស។ គ្រប់គ្រងដោយបុរសៗ។ គេចងក្រងជាកងហ្នឹង ដើម្បីធ្វើដូចជា ភ្ជួរស្រែ ធ្វើការអ្វីៗទាំងអស់ក្នុងការបង្កើនផលហ្នឹង ទៅតាមកងហ្នឹង។ មិនមែនកងឈ្លបកងអីទេ គឺកងធ្វើស្រែចម្ការ។

**ស៖** តើលោកស្រីអាចពន្យល់បានទេ ថាហេតុអីបានជាមានការសរសេរថា "ចម្លងចេញពីសមមិត្ត ហួរ" អ៊ីចឹង? តើ ហួរ ហ្នឹង នៅក្នុងឯកសារហ្នឹង គាត់មានតួនាទីអីដែរ?

**ឆ៖** ខ្ញុំដូចជាអត់បានមានសរសេរ "ចម្លងចេញពី ហួរ" ហ្នឹងទេ។ ឯកសារនេះ គឺខ្ញុំអត់យល់។ ហើយក៏សូមបញ្ជាក់ឆ្នាំ ថ្ងៃទី២១ ខែ៧ តែនេះមិនដឹង៧៧ អីខាងចុងនេះ ខ្ញុំអត់ច្បាស់ មើលអត់ច្បាស់។

**ស៖** បាទ ខ្ញុំអានសំណៅជាភាសាបារាំង គឺសរសេរថា "ធ្វើនៅជាងទង, ថ្ងៃទី២១ ខែ៧ ឆ្នាំ ៧៧"។ ខ្ញុំបញ្ជាក់ថា យើងមានឯកសារផ្សេងមួយទៀត គឺឯកសារ E3/4164, ERN ជាភាសាបារាំងគឺ 00937104, ជាភាសាអង់គ្លេស 00973147, ជាភាសាខ្មែរ 00099387 សូមទោសគឺ 00079337

ទៅដល់ 338 ហើយឈ្មោះដំបូងដែលមាននៅក្នុងបញ្ជីហ្នឹងគឺឈ្មោះ នាង ដាំ ដែលហៅថា ជាង ដាំ នៅក្នុងភាសាអង់គ្លេសដាក់ថា ជាង ដាំ។ មានការបញ្ជាក់ថា កាលបរិច្ឆេទចូលទៅអប់រំគឺ ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៧ សូមទោសគឺ ២០ កក្កដា ៧៧។ តើលោកស្រីមាននឹកឃើញឡើងវិញទេត្រង់ចំណុចនេះ?

[០៩:២៧:២៧]

**ធ៖** ខ្ញុំសូមទោស ខ្ញុំអត់យល់ន័យថារឿង ដាំ ហ្នឹងយ៉ាងម៉េច ហើយក៏ទាក់ទងជាមួយនឹងនាងខ្ញុំនៅឆ្នាំ៧៧ ព្រោះ៧៧ ខ្ញុំនៅក្នុង ធ្វើការងារនៅក្នុងឃុំនៅឡើយ។ ឯក្របខ័ណ្ឌគាត់នៅក្រាំងតាចាន់ គឺជាក្របខ័ណ្ឌរបស់ស្រុក។ អ៊ីចឹងបានខ្ញុំមិនយល់ ហើយក៏ខ្ញុំអត់នឹកឃើញ។

**ស៖** លោកស្រីសាក្សី ខ្ញុំគិតថាលោកស្រីប្រហែលច្រឡំ នៅពេលដែលខ្ញុំអានឯកសារដែលមានឈ្មោះ នាង ដាំ នេះគឺគាត់ជាអ្នកទោសទេ មិនមែនជាបុគ្គលិកក្រាំងតាចាន់ទេ។ យើងដឹងថា គាត់ជាបុគ្គលិកមន្ទីរក្រាំងតាចាន់ ក៏ប៉ុន្តែក្រោយមកទៀតគាត់ក្លាយជាអ្នកទោសវិញ។ ហើយយើងទើបតែបានផ្តល់ឯកសារអំពីរបាយការណ៍ហ្នឹង មានហត្ថលេខារបស់លោកស្រី ហើយមានចុះកាលបរិច្ឆេទដូចគ្នា។ អ៊ីចឹងខ្ញុំមើលទៅ គឺថាពេលហ្នឹងហើយដែលគាត់ត្រូវបានគេចាប់ដាក់ឃុំនៅក្រាំងតាចាន់នោះ។ តើលោកស្រីអាចពន្យល់បានទេ ត្រង់ចំណុចនេះ?

**ធ៖** ចាស ព្រោះ ដាំ ហ្នឹងមិនមែននៅក្នុងឃុំជាងទងទេ តែខ្ញុំស្គាល់ តែមិនមែននៅក្នុងឃុំជាងទងទេ គាត់នៅឃុំត្រពាំងធំខាងជើង។ ហេតុអ្វីបានជាមកទាក់ទងខ្ញុំ បានខ្ញុំមិនយល់។ តែហត្ថលេខាអាហ្នឹងសរសេរបានទាំងអស់។

**ស៖** ខ្ញុំចូលទៅចំណុចផ្សេង។ លោកស្រីសាក្សីនៅពេលដែលសហចៅក្រមស៊ើបអង្កេតស្តាប់ចម្លើយលោកស្រីនោះ លោកស្រីឆ្លើយថាពេលខ្លះនុ៎ង លោកស្រីមិនស្តាប់បញ្ជាដែលលោកស្រីបានទទួលពីថ្នាក់លើទេ។ ជាពិសេសនោះ លោកស្រីធ្លាប់លាក់ស្រូវអង្ករ តើលោកស្រីអាចបញ្ជាក់ពីចំណុចនេះឡើងវិញបានទេ?

**ធ៖** ចាស ខ្ញុំសូមជម្រាប ដោយបានកន្លងមក ផែនការមានមែនពីលើ តែផែនការខ្លះ ឧទាហរណ៍ជាក់ស្តែង ដូចជាការហូបចុករបស់ប្រជាជនខ្វះខាត ហើយពេលដែលធ្វើស្រូវអង្ករបាន ខ្ញុំអាចធ្វើបញ្ជីបញ្ជូនអត់អស់ លាក់ទុកខ្លះ ដើម្បីផ្គត់ផ្គង់នៅក្នុងឃុំឱ្យប្រជាជនបានហូបគ្រប់គ្រាន់។ នេះជាការពិត។

[០៩:៣១:១៧]

**ស៖** តើលោកស្រីលាក់ស្រុកហ្នឹង គឺវាប្រឆាំងទៅនឹងការណែនាំរបស់ថ្នាក់ស្រុកមែនទេ?

**ឆ៖** ចាស វាអាចជាប្រឆាំង តែខ្ញុំសង្ឃឹមថា ឲ្យប្រជាជនហូបចុកបាន វាមិនមានបញ្ហាអី។

**ស៖** តើលោកស្រីលាក់ស្រូវអង្ករហ្នឹងប៉ុន្មានដងដែរ? ហើយហេតុអ្វីបានជាលោកស្រីលាក់ហ្នឹង?

**ឆ៖** ចាស ការលាក់របស់ខ្ញុំ ខ្ញុំលាក់មិនមែនជាច្រើនដងប៉ុន្មានទេ ព្រោះពេវេលាហ្នឹង ក៏វាខ្លីដែរក្នុងសហករណ៍។ ខ្ញុំលាក់អាចពីរបីដងប៉ុណ្ណោះ។ ការលាក់ គឺលាក់នៅនឹងវត្តលោក។

**ស៖** តើលោកស្រីធ្លាប់សង្កេតឃើញថា មានមនុស្សស្លាប់ដោយសារតែហូបចុកមិនគ្រប់គ្រាន់ទេ?

**ឆ៖** ចាស អាចមាន ព្រោះមិន ថាមិនហូបគ្រប់គ្រាន់ក៏ថាបាន។ មកពីហូបមិនគ្រប់គ្រាន់ បានមានជំងឺ ស្លាប់ដោយមិនមានជំងឺ មិនមែនស្លាប់ដោយអត់បាយទេ។ នេះខ្ញុំជម្រាប តែក្នុងក្របខ័ណ្ឌដែលខ្ញុំនៅនេះឯង។

**ស៖** ខ្ញុំមិនឲ្យលោកស្រីនិយាយស្មានទេ ខ្ញុំឲ្យលោកស្រីនិយាយពីអ្វីដែលលោកស្រីដឹង។ ខ្ញុំចង់ដឹងថាតើរឿងដែលមានមនុស្សស្លាប់ដោយអត់អាហារហ្នឹងមែនទេ? ហើយមានការខ្វះខាតស្បៀងអាហារមែនទេ?

**ឆ៖** ចាស ទី១ ការខ្វះខាត គឺវាមានហើយ ប៉ុន្តែដោយឡែកក្នុងឃុំជាងទងនេះ ការខ្វះខាតមិនសូវមានប៉ុន្មានទេ។ ឯទី២ ការស្លាប់ដោយអត់អាហារ គឺអត់មានទេនៅក្នុងឃុំជាងទង។ អត់មានទេ។

[០៩:៣៤:២០]

**ស៖** ខ្ញុំមិនយល់ចម្លើយលោកស្រីទេ។ មុននេះលោកស្រីនិយាយថា ប្រហែលជាមានមនុស្សស្លាប់ដោយសារតែហូបចុកមិនគ្រប់គ្រាន់ ហើយធ្វើឲ្យមនុស្សខ្លះធ្លាក់ខ្លួនឈឺ អ៊ីចឹងមនុស្សឈឺហ្នឹងលោកស្រីចង់និយាយថា នៅកន្លែងណាក៏ឈឺដែរ លើកលែងនៅឃុំលោកស្រីទេ អត់មានមនុស្សឈឺអ៊ីចឹងមែនទេ?

**ឆ៖** មិនមែនទេ ចាស។ ឈឺមាន ឃុំខ្ញុំក៏មានដែរ ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា ការអត់អាហារស្លាប់នៅក្នុងឃុំខ្ញុំ គឺអត់មានទេ។ គ្រាន់តែបើថា ហូបមិនបានសូវគ្រប់គ្រាន់បរិបូរអី គឺអត់មានទេ អត់បានគ្រប់គ្រាន់បរិបូរទេ។ ត្រង់នេះ ដែលខ្ញុំចង់និយាយថា បើស្លាប់ដោយហូបមិនគ្រប់គ្រាន់ឬអី អាហ្នឹងខ្ញុំមិនបានជម្រាបការពិតទេ ព្រោះខ្ញុំមិនបានឃើញជាក់ស្តែង។

**ស៖** តើស្ថានភាពកើតហ្នឹងមានដូចគ្នាទូទាំងស្រុក ឬក៏នៅកន្លែងផ្សេងហ្នឹងវាអាក្រក់ជាង ឬក៏ល្អជាងយ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនសូវបានដឹងពីកន្លែងដទៃដែរ។

**ស៖** តើលោកស្រីមិនដែលនិយាយអំពីបញ្ហាបង្កបង្កើនផលនៅថ្នាក់ស្រុកទេ មែនទេ នៅពេលដែលមានប្រជុំនៅថ្នាក់ស្រុកនោះ មិនដែលមានការលើកឡើងអំពីបញ្ហាហ្នឹងទេមែនទេ?

**ឆ៖** ចាស ប្រជុំនៅថ្នាក់ស្រុកមានលើកតើ លើកពីការបង្កបង្កើនផល ធ្វើស្រែវស្សា ដាំដំណាំរួមផ្សំ និងធ្វើស្រែប្រាំងដើម្បីរកស្បៀងអាហារមកហូបបង្គ្រប់។

**ស៖** សំណួរចុងក្រោយលោកស្រីសាក្សី។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានស្តាប់ចម្លើយលោកស្រី ពេលនោះគេសួរលោកស្រីពាក់ព័ន្ធទៅនឹងចំណារនៅលើឯកសារមួយដែលមានដាក់ពាក្យថា "កម្ទេច"។ នៅពេលដែលគេអនុវត្តពាក្យ "កម្ទេច" នេះចំពោះអ្នកដែលគេចាប់ខ្លួន ឃុំខ្លួន ឬក៏ចាត់ទុកថាជាខ្មាំងនោះ តើពាក្យថា "កម្ទេច"នេះ វាមានន័យបែបណាដែរ?

**ឆ៖** ខ្ញុំយល់ថា "កម្ទេច" ហ្នឹង ជាការចាប់ខ្លួន ឬបោសសម្អាត។

[០៩:៣៨:០៥]

**ស៖** អ៊ីចឹងពាក្យថា "បោសសម្អាត" នេះ មានន័យថាម៉េចដែរ?

**ឆ៖** "បោសសម្អាត" វាមានច្រើនដែរ។ បោសសម្អាត មួយ ហៅថា "ចាប់"។ បោសសម្អាត មួយទៀត ហៅថា បោសសម្អាតគំនិតចាស់ អ៊ីចាស កសាងគំនិតថ្មី។

**ស៖** លោកស្រីសាក្សី បើនរណាម្នាក់គេបញ្ជូនទៅក្រាំងតាចាន់ ហើយមានបញ្ជាមកថា ឲ្យកម្ទេច បើតាមការយល់ដឹងរបស់លោកស្រីហ្នឹង ពេលដែលគេប្រើពាក្យថា "កម្ទេច" នៅកន្លែងហ្នឹងតើមានន័យថាយ៉ាងម៉េច?

**ឆ៖** អាហ្នឹងខ្ញុំមិនដឹងដែរ ដូចខ្ញុំលើកខាងដើមហើយ។ បោសសម្អាត ឬកម្ទេច ខ្ញុំគ្រាន់តែឮ តែខ្ញុំមិនដែលបានទៅជួប ទៅឃើញ ឬក៏ធ្វើទេ។

**ស៖** លោកស្រីការកត់សម្គាល់ចុងក្រោយរបស់ខ្ញុំ។ ចម្លើយរបស់លោកស្រីដែលមាននៅក្នុងឯកសារលេខ E319/12.3.2 ចម្លើយ២៦៤ ពាក្យថា "កម្ទេច" នេះមានន័យថា "សម្លាប់"។ លោកស្រីឃើញទេ នៅចម្លើយទី២៦៤ លោកស្រីដាក់ថាពាក្យថា "កម្ទេច" នេះគឺសម្លាប់ហើយ។

**ឆ៖** ចាស ឃើញ។

**ស៖** ប្រសិនបើលោកស្រីមិនមានយោបល់អីពាក់ព័ន្ធទៅនឹងសំណួរអម្បាញ់មិញនេះទេ។ អ៊ីចឹងខ្ញុំសូមបញ្ចប់ត្រឹមហ្នឹងហើយ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។ ខ្ញុំគ្រាន់តែបញ្ជាក់ថា គឺថាលោកស្រីបាននិយាយពាក្យហ្នឹងមែន នៅពេលដែលចៅក្រមស៊ើបអង្កេតសួរលោកស្រីនោះ។ ខ្ញុំមិនមែនបង្កើតពាក្យហ្នឹងដោយខ្លួនឯងទេ។ អ្វីដែលខ្ញុំអានទូរចម្លើយហ្នឹង គឺថាចម្លើយហ្នឹង គឺ២៦៤ហ្នឹង គឺតើជាចម្លើយរបស់លោកស្រីខ្លួនឯងផ្ទាល់ ឬក៏ខាងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គាត់ជាអ្នកបង្កើតខ្លួនឯងទេ ពាក្យហ្នឹង?

**ឆ៖** ខ្ញុំឆ្លើយផ្ទាល់មែន ខ្ញុំឆ្លើយតាមពាក្យរបស់ ប្រាក់ ដែលប្រាប់មក ចាស។ តាមសេចក្ដីសម្រេចចិត្តរបស់ ប្រាក់។

[០៩:៤១:៥២]

**ស៖** អ្នកណាជាអ្នកប្រាប់លោកស្រីហ្នឹង?

**ឆ៖** ប្រាក់ – ឈ្មោះ ប្រាក់។

**ស៖** ប្រាក់ ហ្នឹងជាអ្នកណាដែរ?

**ឆ៖** ប្រាក់ ហ្នឹងជាថ្នាក់តំបន់។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំអស់សំណួរហើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។

ឥឡូវនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដែលដំបូងនេះ ផ្ដល់ទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីឱកាសតាំងសំណួរដេញដោលចំពោះសាក្សី ខឹម ហឿន។ បាទ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។ សូមជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំឈ្មោះ វ៉ិចទ័រ កូប៉េ។ ខ្ញុំជាមេធាវីអន្តរជាតិរបស់លោក នួន ជា ហើយខ្ញុំមានសំណួរមួយចំនួនដែលខ្ញុំត្រូវសាកសួរទៅកាន់លោកស្រី។

[០៩:៤៣:១៤]

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជាដំបូង ខ្ញុំសូមធ្វើការសួរបន្តពីអ្វីដែលលោកចៅក្រមបានសួរនៅព្រឹកនេះ។ លោកស្រីបាននិយាយថា មានពេលខ្លះលោកស្រីលាក់ស្រូវ ដើម្បីផ្គត់ផ្គង់ប្រជាជនរបស់លោកស្រី។ នៅពេលដែលលោកស្រីនិយាយថា “ប្រជាជនរបស់ខ្ញុំ”ហ្នឹង តើលោកស្រីចង់សំដៅទៅលើអ្នកណាដែរ? តើលោកស្រីមានន័យយ៉ាងដូចម្ដេចដែរ?

**លោកស្រី ខឹម ឿន៖**

**ឆ៖** ចាស សូមជម្រាបថា “ប្រជាជនរបស់ខ្ញុំ”ហ្នឹង ខ្ញុំចង់និយាយថាប្រជាជនដែលរស់នៅក្នុងឃុំខ្ញុំ ចាស។

**ស៖** នៅពេលដែលលោកស្រីនិយាយអំពី “ប្រជាជនខ្ញុំ”ហ្នឹង តើប្រជាជនទាំងអស់ហ្នឹង រួមបញ្ចូលទាំងប្រជាជនដែលគេជម្លៀសមកពីភ្នំពេញ និងមកពីទីរួមខេត្តតាកែវដែលគេចាត់ទុកថាជាប្រជាជនថ្មីដែរឬទេ?

**ឆ៖** ចាស រួមទាំងអស់។

**ស៖** ដូច្នេះ ដើម្បីផ្គត់ផ្គង់ចំណីអាហារដល់ប្រជាជននៅក្នុងឃុំរបស់លោកស្រី លោកស្រីអត់បែងចែកទេ រវាងប្រជាជនថ្មី និងប្រជាជនចាស់។ អ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** ចុះការព្យាបាលនៅមន្ទីរពេទ្យសម្រាប់អ្នកដែលឈឺ ឬក៏ការផ្គត់ផ្គង់ឱសថចំពោះប្រជាជនដែលមានជំងឺ តើអ្នកស្រីបែងចែកដែរឬទេ រវាងប្រជាជនថ្មីនិងប្រជាជនចាស់ នៅពេលដែលពួកគេចង់ព្យាបាលនៅមន្ទីរពេទ្យ ឬក៏ពួកគេចង់បានឱសថ លោកស្រីមានបែងចែកទេ?

[០៩:៤៥:៣៣]

**ឆ៖** ចាស អត់ទេ ខ្ញុំបញ្ជូនទៅ អាហ្នឹងភារកិច្ចរបស់ពេទ្យ តែអត់មានបែងចែកទេ។

**ស៖** ចុះការអប់រំវិញ តើមានភាពខុសគ្នា ឬក៏មានការប្រព្រឹត្តខុសៗគ្នាចំពោះកូនរបស់ប្រជាជនមកពីភ្នំពេញ និងកូនរបស់ប្រជាជនចាស់? ហើយថាតើក្មេងៗនៅក្នុងឃុំរបស់លោកស្រីហ្នឹងបានចូលរៀនដែរឬទេក៏អត់?

**ឆ៖** ចាស ការអប់រំ រួមទាំងការចូលរៀន ហ្នឹងរួមគ្នាទាំងអស់ គឺអត់មានបែងចែកទេ។

**ស៖** លោកស្រី អ៊ីចឹងខ្ញុំអាចនិយាយបានទេថា នៅក្នុងឃុំរបស់លោកស្រី គឺលោកស្រីអត់មានរើសអើងជាមួយប្រជាជនថ្មីទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** នៅក្នុងឃុំរបស់លោកស្រី តើលោកស្រីធ្លាប់បញ្ជូនមនុស្សទៅអប់រំ ឬក៏ទៅរៀនសូត្រដោយសារតែពួកគេជាប្រជាជនថ្មីដែរឬទេ? ឬមួយក៏ទាល់តែប្រជាជនហ្នឹងធ្វើអីខុស ទើបលោកស្រីបញ្ជូនពួកគេទៅរៀនសូត្រ?

**ឆ៖** ចាស សូមបញ្ជាក់ថា ខ្ញុំអត់មានបានបញ្ជូនដោយខ្លួនឯងទេ។ មានធ្វើខុស គឺរាយការណ៍ជូនថ្នាក់លើ ហើយមានបញ្ជាពីលើបានបញ្ជូនចាស។

**ស៖** ខ្ញុំយល់លោកស្រី ប៉ុន្តែខ្ញុំចង់ដឹងថា លោកស្រីដឹងអំពីស្ថានភាពនៅក្នុងឃុំ ឬក៏ឃុំដទៃទៀតនៅក្នុងតំបន់១០៥ គឺថាប្រជាជនត្រូវបានគេដាក់ទណ្ឌកម្ម ឬក៏គេធ្វើទារុណកម្ម ដោយសារតែគាត់គ្រាន់តែជាប្រជាជនថ្មី តើមានដែរឬទេ?

**ឆ៖** ចាស ខ្ញុំដឹងតែឃុំជាងទង គឺអត់មានទេចាស។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំមានសំណួរពីរខ្លីៗទាក់ទងទៅនឹងបញ្ហាស្បៀងអាហារ។ ខ្ញុំចង់អានឲ្យលោកស្រីស្តាប់នូវសំណួរចម្លើយ ដែលលោកស្រីបានផ្តល់ទៅសហចៅក្រមស៊ើបអង្កេតគឺ E319/12.3.2។ គឺសំណួររបស់លោកស្រី សំណួរ៥៦ ប្រធានបទនេះគឺនិយាយអំពី តាម៉ុក។ គេសួរថាលោកស្រីស្គាល់ តាម៉ុក ដែរឬទេ? លោកស្រីឆ្លើយថា៖ "ចាស ខ្ញុំស្គាល់គាត់ផ្ទាល់។ មានពេលខ្លះគាត់ចុះមកមើលកន្លែងបាយនៅតាមសហករណ៍ គាត់បានសួរប្រជាជនអំពីការហូបចុកឆ្អែតដែរឬទេ។ តាម៉ុកចុះមើលគ្រប់កន្លែងទាំងអស់ ខ្ញុំធ្លាប់ជួប តាម៉ុក"។ ខ្ញុំដឹងថាវាកើតឡើងកន្លងមកហើយ យូរឆ្នាំមកហើយ ប៉ុន្តែលោកស្រីអាចបញ្ជាក់ឲ្យបានច្បាស់ដែរឬទេ ថាតើ តាម៉ុក មានបានសួរប្រជាជន ឬក៏គាត់សួរលោកស្រីអំពីការហូបចុកដែរឬទេ? ខ្ញុំចង់សំណួរថាតើគាត់ព្រួយបារម្ភអំពីការបញ្ហាស្បៀងអាហារ ការហូបចុកហ្នឹងដែរឬទេ?

[០៩:៥០:០៥]

**ឆ៖** ចាស គាត់បានចុះផ្ទាល់ ព្រោះគាត់ តែចុះ ចុះដល់ភូមិ ដល់សហករណ៍ហ្នឹង។ ទៅសួរប្រជាជនផ្ទាល់ មិនមែនសួរខ្ញុំទេ។

**ស៖** អ៊ីចឹងលោកស្រីយល់ថាគាត់ព្រួយបារម្ភ ឬមួយក៏គាត់គិតអំពីបញ្ហាស្បៀងអាហាររបស់ប្រជាជន អ៊ីចឹងមែនទេ?

**ឆ៖** ចាស គាត់ព្រួយបារម្ភ តាមមើលគាត់ព្រួយបារម្ភដែរ។

**ស៖** តើលោកស្រីធ្លាប់ឃើញសកម្មភាពរបស់គាត់ នៅពេលដែលគាត់ឃើញ ឬក៏តើគាត់មានចំណាត់ការអ្វីចំពោះបញ្ហាស្បៀងអាហារហ្នឹងដែរឬទេ?

**ឆ៖** តាមខ្ញុំឃើញ ខ្ញុំថាគាត់មានចំណាប់អារម្មណ៍ខាងខ្វះខាតស្បៀងអីដែរ។ ដល់ឃើញគាត់យកពីកន្លែងផ្សេងៗទៅផ្គត់ផ្គង់កន្លែងខ្វះ។

**ស៖** លោកស្រី បើតាមលោកស្រីចាំ តើគោលដៅនៃរបបមួយនោះ គឺថាគេមានគោលដៅធានាថា ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានបាយហូបគ្រប់គ្រាន់ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំមានយោបល់ ចំពោះតែក្នុងកន្លែងដែលខ្ញុំរស់នៅទេ កន្លែងផ្សេងទៀត តែខ្ញុំក្តាប់អត់បានដែរ។

[០៩:៥២:៤០]

**ស៖** អ៊ីចឹងនៅក្នុងតំបន់របស់លោកស្រី អ៊ីចឹងរបបហ្នឹង របបកម្ពុជាប្រជាធិបតេយ្យមានគោលបំណងចង់ឲ្យប្រជាជននៅក្នុងតំបន់របស់លោកស្រីហ្នឹងមានអាហារហូបចុកគ្រប់គ្រាន់ អ៊ីចឹងមែនទេ?

**ឆ៖** ចាស ចង់ឲ្យមានអាហារហូបគ្រប់គ្រាន់ តែវាមានការខ្វះខាតតិចតួចម្ហូបអីជាដើម។

**ស៖** ប្រសិនបើដូច្នេះមែន ថាតើមានការបង្គាប់បញ្ជាពីថ្នាក់លើឲ្យកែប្រែ ឬឲ្យដោះស្រាយបញ្ហាហ្នឹងឲ្យបានឆាប់រហ័សដែរឬទេ?

**ឆ៖** ចាស មាន មានការអប់រំពីលើឲ្យខំដោះស្រាយជីវភាពឲ្យប្រជាជន។

**ស៖** លោកស្រី កាលពីម្សិលមិញ គេសួរលោកស្រីអំពីការលួចអាហារដោយប្រជាជនដែលស្រេកឃ្លាន ហើយលោកស្រីចង់និយាយ គេចាត់ទុកថាជាបទល្មើសស្រាល? ប្រសិនបើមានអ្នកប្រព្រឹត្តបទល្មើសស្រាល ឧទាហរណ៍ដូចជាបុគ្គលហ្នឹងគាត់លួចដំឡូងដោយសារគាត់ឃ្លានជាដើមហ្នឹង តើមានការដាក់ទណ្ឌកម្ម ឬក៏មានអ្វីកើតឡើងចំពោះបុគ្គលហ្នឹងដែរឬទេ ដោយសារតែគាត់ឃ្លាន គាត់លួចដំឡូងអ៊ីចឹង តើមានការដាក់ទណ្ឌកម្មអ្វីដែរឬទេ?

**ឆ៖** ចាស អត់មានទេ មានតែអប់រំប្រាប់ ថ្ងៃក្រោយត្រូវអត់ៗទាំងអស់គ្នា មានៗទាំងអស់គ្នា ចាស។

[០៩:៥៥:០០]

**សៈ** តើលោកស្រីបានដឹងអំពីហេតុការណ៍ ឬក៏ឧទាហរណ៍ដែលកើតឡើងនៅក្នុងឃុំរបស់លោកស្រី ឬក៏ឃុំនានានៅក្នុងតំបន់១០៥ ដែលថា មានប្រជាជនត្រូវបានគេសម្លាប់ដោយសារតែគាត់លួចដូង ឬក៏លួចដំឡូងជាដើម តើមានទេ?

**ធៈ** ចាស ខ្ញុំក្លាប់អត់បាន បានតែត្រឹមក្នុងឃុំនេះ។

**សៈ** តើលោកស្រីមានអនុវត្តមាគ៌ាបក្សដែរឬទេ នៅពេលដែលដាក់ទណ្ឌកម្មទៅលើអ្នកដែលលួចស្បៀងអាហារដោយសារតែពួកគេឃ្លានហ្នឹង លោកស្រីមានអនុវត្តតាមមាគ៌ាបក្សដែរឬទេ?

**ធៈ** ខ្ញុំអត់មានដែលបានអប់រំ ដាក់ទណ្ឌកម្មឲ្យអ្នកដែលលួចជាដូង ជាដំឡូង ដែលថាលួចពីការស្រែកឃ្លានអី អត់ដែលមានធ្វើទណ្ឌកម្មទេ ចាស មានតែអប់រំ បើយើងឃ្លានៗទាំងអស់គ្នា អត់ទាំងអស់គ្នា។ ក្រោយៗកុំធ្វើអីចឹងទៀត តែប៉ុណ្ណឹង។

**សៈ** នៅក្នុងស្ថានភាពបែបនេះ បានន័យថាលោកស្រីមិនដាក់ទណ្ឌកម្មទៅលើអ្នកណាមួយនោះ តើលោកស្រីធ្វើបែបនេះតាមបញ្ជា ឬក៏តាមបង្គាប់របស់ថ្នាក់លើ ឬមួយយ៉ាងម៉េច?

**ធៈ** ចាស តាមការណែនាំពីលើថាបើ ការលួចហូបចុកខ្វះខាត គឺមិនត្រូវធ្វើទារុណកម្ម ឬដាក់ទណ្ឌកម្មអីដល់ប្រជាជន។ ដូច្នេះ ខ្ញុំអនុវត្តតាមហ្នឹង ធ្វើតាមហ្នឹង។

**សៈ** តើលោកស្រីអនុវត្តការបញ្ជា ការបង្គាប់ហ្នឹងដោយមិនគិតថា ប្រជាជនហ្នឹងជាប្រជាជនថ្មី ឬក៏ប្រជាជនចាស់ អ៊ីចឹងមែនទេ?

**ធៈ** ចាស។

[០៩:៥៧:៤៦]

**សៈ** សំណួរមួយចុងក្រោយទាក់ទងទៅនឹងប្រធានបទចំណីអាហារនេះ តើលោកស្រីធ្លាប់មានធ្លាប់ជួបនូវស្ថានភាពដែលថា ប្រជាជនជាជនជាតិចាម ហើយត្រូវបានបង្ខំឲ្យហូបសាច់ជ្រូកដោយផ្ទុយពីបំណងរបស់គាត់ដែរឬទេ?

**ធៈ** ចាស អត់ទេ អត់ដែលជួបទេ អត់មានចាម។

**សៈ** សូមអរគុណលោកស្រីសាក្សី។ ខ្ញុំចង់ប្តូរទៅប្រធានបទថ្មីមួយដែលគេសួរសំណួរលោកស្រី អំពីគោលនយោបាយរៀបអាពាហ៍ពិពាហ៍នៅក្នុងឃុំរបស់លោកស្រី។ ខ្ញុំសូមអាននូវកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីមួយចំនួន ហើយខ្ញុំនឹងសួរលោកស្រីបន្តអំពីមតិយោបល់ ឬក៏ការយល់

ឃើញរបស់លោកស្រី។ ជាដំបូង ខ្ញុំសូមចាប់ផ្ដើមជាមួយនឹងសំណួរ១១១។ ខ្ញុំសូមសួរសំណួរលោកស្រីដំបូង។ ខ្ញុំសូមដកស្រង់សំណួររបស់លោកស្រី "ក្នុងរបបខ្មែរក្រហម បក្សគឺជាអ្នករៀបចំការរៀបការ តើគេរៀបចំការរៀបការនេះយ៉ាងដូចម្ដេច? តើមានការពិភាក្សានៅក្នុងថ្នាក់តំបន់ឬទេ ឬក៏ថ្នាក់សហករណ៍ ឬក៏ថ្នាក់ភូមិជាអ្នកសម្រេច?" ផ្នែកទី២ នៃចម្លើយរបស់លោកស្រីគឺថា៖ "អ្នកដែលស្រឡាញ់គ្នាគេមកប្រាប់យើង ហើយយើងសរសេរឈ្មោះបញ្ជូនទៅតំបន់។ ហើយអ្នកដែលមិនព្រមគឺប្រាប់ថាមិនព្រម ហើយយើងនឹងឆូតឈ្មោះចោល"។ នៅក្នុងចម្លើយ១១២ លោកស្រីបានឆ្លើយថា៖ "បើប្រជាជនថ្មីត្រូវរៀបការជាមួយនឹងប្រជាជនចាស់ ហើយបើមានអ្នកណាបដិសេធ គេនឹងឆូតឈ្មោះចេញ ពីព្រោះអ្នកខ្លះមានប្រវត្តិរូបមិនល្អ"។ ចម្លើយ១១៤៖ "សម្រាប់កន្លែងរបស់ខ្ញុំ គឺខ្ញុំមើលសភាពការណ៍ថា កំលោះម្នាក់ហ្នឹង និងក្រមុំម្នាក់ហ្នឹង ធ្វើការចូលគ្នាឬទេ"។ ហើយនៅក្នុងចម្លើយ១១៦៖ "អ្នកដែល -- តើមានអីកើតឡើង ប្រសិនបើគេបដិសេធ? កន្លែងរបស់ខ្ញុំអត់មានរឿងបែបនេះទេ គឺថាអ្នកទាំងអស់សុទ្ធតែស្គាល់គ្នា ព្រោះកន្លែងរបស់ខ្ញុំវាតូច។ យើងរៀបចំឲ្យរៀបការជាមួយគ្នា ហើយសាមីខ្លួនយល់ព្រម ប៉ុន្តែបើថ្នាក់លើមិនយល់ព្រមនោះ ពួកគេក៏ពុំអាចរៀបការជាមួយគ្នាបានដែរ"។ លោកស្រី ខ្ញុំបានអាននូវសម្រង់ប្លួនចេញពីចម្លើយរបស់លោកស្រី ថាតើខ្ញុំអាចសន្និដ្ឋានបានទេថានៅក្នុងឃុំរបស់លោកស្រី គឺមិនមានហេតុការណ៍ដែលថាប្រជាជនត្រូវបានគេបង្ខំឲ្យរៀបការទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

[១០:០១:២៨]

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ ប្រសិនបើបុរស ឬក៏នារី មិនចង់រៀបការជាមួយអ្នក បុរស ឬក៏នារីដទៃទៀត អ៊ីចឹងពួកគាត់អាចប្រាប់គេថា មិនចង់អ៊ីចឹងមែនទេ? ហើយបន្ទាប់មកទៀត គឺគាត់មិនចាំបាច់ត្រូវរៀបការ អ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** សំណួរមួយចុងក្រោយក្នុងផ្នែករៀបការហ្នឹង កាលពីម្សិលមិញ លោកស្រីបាននិយាយអំពីប្រជាជនដែលលែងគ្នាក្រោយពីរៀបការ។ ថាតើលោកស្រីនិយាយអំពីការលែងលះគ្នា ក្នុងពេលដែលលោកស្រីនៅជាមេឃុំ ឬក៏លោកស្រីនិយាយអំពីការលែងលះគ្នាក្រោយឆ្នាំ១៩៧៩?

**ឆ៖** ចាស ខ្ញុំចង់បានន័យថា ការរៀបការដែលរៀបគូស្មគ្រចិត្តហើយហ្នឹង ក៏អាចខ្លះមានលែងលះគ្នាក៏មាន។ ឯប្រជាជនចាស់ហ្នឹងក៏មានអ៊ីចឹងដូចគ្នាដែរ ធម្មតាហ្នឹង។

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ តើលោកស្រីចង់និយាយអំពីការលែងលះគ្នាក្នុងអំឡុងចន្លោះឆ្នាំ៧៥ ដល់៧៩ អ៊ីចឹងមែនទេ? ថាតើក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង គេអនុញ្ញាតឲ្យប្រជាជនលែងលះគ្នា អ៊ីចឹងមែនទេ?

**ឆ៖** ចាស ក្នុងចន្លោះ៧៥-៧៧ហ្នឹង គឺមានការរៀបចំហើយហ្នឹង មានលះលែងគ្នា ទាំងប្រជាជនចាស់ ទាំងប្រជាជនថ្មី មានដូចគ្នា តែខ្ញុំមិនបានជាដឹងជាចំនួនទេ ប៉ុន្តែមាន ចាស។ ឈ្លោះទាស់ទែងគ្នា ហើយក៏គ្មានធ្វើទារុណកម្មអីដែរ ដោយការស្ម័គ្រចិត្ត។

[១០:០៤:០៥]

**ស៖** ខ្ញុំដឹងថា វាជាហេតុការកើតឡើងយូរឆ្នាំណាស់មកហើយ ប៉ុន្តែតើលោកស្រីចាំអំពីប្តីប្រពន្ធនៅក្នុងឃុំរបស់លោកស្រីដែលពួកគេលែងលះក្នុងចន្លោះឆ្នាំ៧៥ ដល់ ៧៩។ តើលោកស្រីចាំថាមានដែរឬទេ?

**ឆ៖** ចាស មាន តែខ្ញុំមិនចាំច្បាស់កន្លែង ឬក៏ពេលវេលាទេ។ តែមាន ដូចខ្ញុំជម្រាបខាងដើម អ៊ីចឹង មាន។

**ស៖** តើពួកគេលែងលះ នៅពេលដែលលោកស្រីធ្វើជាមេឃុំហ្នឹងមែនទេ?

**ឆ៖** ចាស។

**ស៖** ក្នុងនាមជាមេឃុំ តើលោកស្រីត្រូវចាំបាច់ត្រូវអនុញ្ញាតឲ្យពួកគេលែងលះគ្នាដែរឬទេ នៅពេលដែលប្តីប្រពន្ធហ្នឹងចង់លែងលះគ្នា?

**ឆ៖** ចាស ទោះមិនអនុញ្ញាតក៏គេលែង ដូច្នេះខ្ញុំអត់មានបញ្ហាទំនាស់ទេ គ្រាន់ថាអប់រំឲ្យយកគ្នាវិញ ស្រុះស្រួលគ្នាវិញ ហើយគេថាយកគ្នាមិនបាន អាហ្នឹងក៏តាមរៀងខ្លួន អត់មានទោសមានពៃរ៍អីទេ។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវនេះខ្ញុំចង់បន្តទៅប្រធានបទថ្មី គឺប្រធានបទអំពីមេស្រុកឈ្មោះ ខុម។ សំណួរ២៨៥ របស់លោកស្រីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត លោកស្រីបាននិយាយថា ខុម មានបញ្ហាឆ្កួត។ តើលោកស្រីអាចរៀបរាប់បានទេ ថាតើលក្ខណៈបុគ្គលរបស់ ខុម ហ្នឹងជាមនុស្សបែបណាដែរ?

[១០:០៦:៥១]

**ឆ៖** ចាស ខុម ជាមនុស្សដែលគាត់មិនដូចយើងគ្រប់គ្នា គាត់មានរបៀបហៅថាប្រសៃប្រសាទ ឬក៏ពាក្យគេថា "ឆ្កួត" ប៉ុន្តែមិនជាប់ ពេលខ្លះឆ្កួត ពេលខ្លះជា។ ហ្នឹងខ្ញុំស្គាល់ប៉ុណ្ណឹង។

**ស៖** តើលោកស្រីដឹងថា ខុម មានបញ្ហាខួរក្បាលហ្នឹង បញ្ហាអ្វីដែរ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ គ្រាន់ឃើញអ៊ីចឹង។

**ស៖** ខ្ញុំយល់ ថាពិបាកក្នុងការបង្ហាញអំពីប្រភេទជំងឺរបស់គាត់ តើលោកស្រី -- ប៉ុន្តែតើលោកស្រីអាចរៀបរាប់អំពីអាកប្បកិរិយារបស់ ខុម បានដែរឬទេ? តើអាកប្បកិរិយាអ្វីរបស់ ខុម ដែលធ្វើឲ្យលោកស្រី ក៏ដូចជាអ្នកដទៃទៀតហ្នឹងយល់ថាគាត់មានបញ្ហាខួរក្បាលនោះ?

**ឆ៖** ខ្ញុំមិនសូវបាននៅជិតដល់ដែរ ដូច្នេះការរៀបរាប់របស់ខ្ញុំក៏វាមិនបានពិតប្រាកដ។ តែខ្ញុំឃើញគាត់ចិត្តច្រើន គាត់នេះ ហ្នឹងឃើញតែប៉ុណ្ណឹងឯង អាកប្បកិរិយាគាត់។

**ស៖** ខ្ញុំយល់ថា វាមិនល្អទេដែលនិយាយអំពីបញ្ហារបស់ខួរក្បាលរបស់បុគ្គលណាម្នាក់ ប៉ុន្តែប្រសិនបើលោកស្រីអាចចាំ តើ ខុម ធ្វើអ្វីខ្លះ? ចង់និយាយថាតើ ខុម មានសកម្មភាពអ្វីខ្លះដែលធ្វើឲ្យលោកស្រីគិតថាគាត់វិកលចរិត?

**ឆ៖** ខ្ញុំពិបាករៀបរាប់ដែរ ប៉ុន្តែខ្ញុំឃើញពេលខ្លះគាត់ដើរ គាត់ដាច់បាយដាច់ទឹកក៏មាន ហើយខ្ញុំមិនបានរស់នៅជិតដិតអី ឃើញម្តងម្កាល មិនអាចរាប់រៀបបានទេ។

[១០:០៩:៣៨]

**ស៖** សំណួរចុងក្រោយអំពី ខុម ដែលខ្ញុំចង់សួរ គឺថាតើលោកស្រីចាំទេថាបញ្ហាជំងឺខួរក្បាលរបស់គាត់ហ្នឹងអាចប៉ះពាល់ទៅដល់សេចក្តីសម្រេចរបស់គាត់នៅក្នុងឃុំ នៅក្នុងស្រុកដែរឬទេ?

**ឆ៖** ចាស ដល់សំណួរនេះ ខ្ញុំក៏ចាប់អារម្មណ៍ដែរ គាត់សម្រេចការងារនៅក្នុងភូមស្រុកអីគឺគាត់មិនសូវបានពិភាក្សា គាត់ច្រើនអត្តនោម័តិដែរ។ ខ្ញុំដឹងបានតែប៉ុណ្ណឹងទេ ចាស។

**ស៖** ខ្ញុំយល់ ប៉ុន្តែខ្ញុំចង់ដឹងថាតើលោកស្រីដឹងដែរឬទេ ថាបញ្ហាខួរក្បាលរបស់គាត់ហ្នឹង វាប៉ះពាល់ដល់សេចក្តីសម្រេច ដែលលោកស្រីត្រូវអនុវត្តហ្នឹង លោកស្រីត្រូវធ្វើហ្នឹង តើវាប៉ះពាល់ដែរឬទេ?

**ឆ៖** ចាស អាច តែខ្ញុំរាប់រៀបមិនបាន ដោយមិនចាំ ភ្លេចបាត់ ពេលយូរពេកហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមើលទៅឃើញថាវាដល់ពេលយើងឈប់សម្រាកហើយ តើលោកប្រធានសម្រេចយ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកស្រី ខឹម បឿន ហើយនិងមេធាវីប្រឹក្សា ឥឡូវនេះដល់ពេលសម្រាកហើយ

យើងសម្រាកចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់កន្លះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សូមលោកស្រី ខឹម ហឿន ជាមួយនឹង រួមទាំងមេធាវីប្រឹក្សាមានវត្តមាននៅកន្លែងផ្តល់សក្ខីកម្មនៅវេលាម៉ោងដប់ និងសាមសិបនាទី។

សម្រាកចុះ។ ម៉ោងដប់ និងសាមសិបនាទី សូមចូលវិញ បាទ។

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ខឹម ហឿន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកស្រីសាក្សី។ មុនពេលដែលយើងឈប់សម្រាក យើងបាននិយាយអំពីឈ្មោះ ខុម។ ឥឡូវនេះ ខ្ញុំចង់សួរលោកស្រីអំពីកម្មាភិបាលតំបន់១០៥។ ដំបូងបំផុតខ្ញុំចង់សួរលោកស្រីអំពីតាគារ។ គេសួរលោកស្រីអំពី តាគារ គឺអ្នកស៊ើបអង្កេតរបស់ការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត សួរលោកស្រីអំពី តាគារ គឺសំណួរ២៩។ ហើយលោកស្រីឆ្លើយទៅនឹងសំណួរនេះថា តាគារត្រូវបានគេចាប់ខ្លួនទៅក្នុងរបបខ្មែរក្រហម។ តើលោកស្រីចាំអំពីហេតុផលដែលគេចាប់ខ្លួន តាគារដែរឬទេ?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេចាស។ អត់ដឹងហេតុផលទេ។

**ស៖** តើលោកស្រីដឹងថា តាគារ មានទំនាក់ទំនងអ្វីជាមួយនឹង ជូ ជេត ហៅ ស៊ី ដែរឬទេ?

**ឆ៖** អត់ច្បាស់ ចាស សុំម្តងទៀតអត់ច្បាស់។

**ស៖** តើលោកស្រីដឹងថា តាគាវ គាត់មានទំនាក់ទំនងអ្វីជាមួយ ជូ ជេត ដែលគេហៅថា ស៊ី នោះដែរឬទេ? គឺ ជូ ជេត ហៅ ស៊ី ដែលជាអតីតមេភូមិភាគបូព៌ានោះដែរទេ?

**ឆ៖** ចាស ខ្ញុំអត់បានដឹងទេ អត់ទាំងស្គាល់ផង។

**ស៖** មិនអីទេ លោកស្រី។ ឥឡូវ ខ្ញុំចង់សួរកម្មាភិបាលមួយរូបទៀត គឺបុគ្គលម្នាក់ឈ្មោះ អ៊ឹម ចែម គឺគេសួរសំណួរលោកស្រីច្រើនអំពីឈ្មោះម្នាក់នេះ។ ហើយខ្ញុំនឹងនិយាយអំពីសំណួរមួយចំនួនដែលគេសួរលោកស្រី គឺសំណួរ៣១២។ ខ្ញុំនឹងអានទាំងសំណួរនិងចម្លើយ។ សំណួរគឺដូចតទៅនេះ៖ "មានសាក្សីនិយាយថា យាយបឿន ជាមនុស្សដែលស ចំណែក អ៊ឹម ចែម ជាមនុស្សដែលខ្មៅ (ស និងខ្មៅ គឺសំដៅមនុស្សចិត្តល្អ និងចិត្តអាក្រក់)។ តើហេតុអ្វីបានជាគេធ្វើការប្រៀបធៀបដូច្នេះ តើលោកស្រីធ្វើការរៀបរាប់អំពីលក្ខណៈរបស់ អ៊ឹម ចែម បានដែរឬទេ?" លោកស្រីឆ្លើយថា៖ "ខ្ញុំមិនអាចរៀបរាប់អំពី អ៊ឹម ចែម នោះទេ ព្រោះខ្ញុំមិនបានដឹងជាក់ស្តែង។ មានសាក្សីខ្លះ យើងត្រូវស្វែងរកការពិតជាលក្ខណៈបុគ្គល ដូច្នេះមិនត្រឹមត្រូវទាំងអស់នោះទេ ព្រោះអ្នកខ្លះ គឺមានទំនាស់ជាបុគ្គល"។ នេះជាចម្លើយរបស់លោកស្រី។ អ្វីដែលខ្ញុំចង់ដឹង គឺថាហេតុអ្វីបានជាមានសាក្សីម្នាក់ ហៅថាលោកស្រីមនុស្ស-ស ផ្ទុយនឹងពីមនុស្សខ្មៅ ដែលសំដៅទៅលើមនុស្សចិត្តល្អ ផ្ទុយពីមនុស្សចិត្តអាក្រក់។ តើលោកស្រីអាចពន្យល់បានទេថាហេតុអ្វី?

[១០:៣៧:០១]

**ប្រធានអង្គជំនុំ៖**

ខឹម បឿន កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ គឺជាសំណួរដែលឲ្យសាក្សីនេះ ឆ្លើយព្រាវៗ អ៊ីចឹងខ្ញុំសូមជំទាស់លោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ប្រសិនបើអ្នកស៊ើបអង្កេត ឬក៏សហចៅក្រមស៊ើបអង្កេតអាចសួរសំណួរបែបនេះបាន ខ្ញុំប្រាកដជាអាចសួរសំណួរបែបនេះបានដែរ។ ប៉ុន្តែខ្ញុំមិនមែនស្នើសុំឲ្យសាក្សីទាយស្មាននោះទេ។ ខ្ញុំគ្រាន់តែចង់ឲ្យសាក្សីគាត់ឆ្លើយអំពីសំណួរចម្លើយរបស់គាត់តែប៉ុណ្ណោះ។ ខ្ញុំសង្ឃឹមថា ខ្ញុំអាចសួរសំណួរនេះបាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៨:០០]

**ប្រធានអង្គជំនុំ៖**

សាក្សីអាចឆ្លើយតបនឹងសំណួរនេះ បាន។ ខឹម ហឿន អាចឆ្លើយតបនឹងសំណួរនេះបាន បើសិន បើលោកស្រីចាំសំណួរដែលបានសួរនេះ។

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ចាស ខ្ញុំសូមជម្រាបដែលលោកបានលើកអម្បាញ់មិញថា ខ្ញុំ ស ហើយអ៊ឹម ចែម ខ្មៅ។ ពាក្យទាំងអស់នេះ គឺមិនមែនខ្ញុំអ្នកកំណត់ថា ស-ខ្មៅ ទេ គឺការពីការលោកស៊ើបអង្កេត លោកបានលើកខ្លួនលោកទេ។ លោកលើកប្រាប់ខ្ញុំ ថាក្រុមស៊ើបការណ៍របស់លោកចុះទៅស៊ើបការណ៍ មានប្រជាជនថាអ៊ីចឹង។ ចាស មិនមែនខ្ញុំទេ។ ដូច្នេះ ខ្ញុំអត់អាចរៀបរាប់បានពី ស-ខ្មៅ ហ្នឹង បានទេ។

[១០:៣៩:០៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំយល់ពីចំណុចនេះ វាពិបាកក្នុងការឆ្លើយអំពីខ្លួនលោកស្រី ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា នៅពេលដែលលោកស្រីធ្វើជាមេឃុំ ហើយក្រោយមកទៀតជា -- ហើយទៅខាងស្រុក តើលោកស្រីជាមនុស្សដែលមានសន្តានចិត្តល្អជាមួយប្រជាជនមែនទេ នៅពេលដែលលោកស្រីធ្វើជាមេដឹកនាំនោះ?

**ឆ៖** ចាស ផ្ទាល់ខ្លួនខ្ញុំ ចេះតែចង់ធ្វើល្អ ប៉ុនសំខាន់អ្នកដទៃគេមើលឃើញ តែខ្ញុំខ្លួនខ្ញុំថាល្អ អ្វីដែលខ្ញុំធ្វើ។

**ស៖** ហើយប្រសិនបើលោកស្រីនិយាយថា បើតាមខ្លួនលោកស្រីផ្ទាល់ លោកស្រីគិតថាល្អ។ តើលោកស្រីអាចរៀបរាប់បានទេ អំពីសកម្មភាព និងអាកប្បកិរិយារបស់លោកស្រីនៅក្នុងចន្លោះឆ្នាំ៧៥ ដល់៧៩? តើអ្វីខ្លះដែលលោកស្រីបានធ្វើនៅពេលនុ៎ងដែលធ្វើឲ្យលោកស្រីនិយាយឥឡូវហ្នឹងថាលោកស្រីជាមនុស្សល្អ?

**ឆ៖** ចាស ខ្ញុំសូមជម្រាប កាល -- តាំងពីឆ្នាំ៧៥ ដល់ ៧៧ហ្នឹង ខ្ញុំក៏មិនចាំបានទាំងអស់ដែរខ្ញុំភ្លេច ម្យ៉ាងទៀតបច្ចុប្បន្នខ្ញុំភ្នែកក៏ងងឹត ត្រចៀកក៏ធ្ងន់ ស្តាប់មិនសូវច្បាស់។ តែខ្ញុំចង់និយាយពីទិសដៅដែលថា ខ្ញុំធ្វើល្អគឺខ្ញុំបានរៀបចំតាមកងដូចជម្រាបពីព្រឹកមិញជាកងកុមារ ជាកងនារី ជាកងយុវជន ជាកងបុរស ពេលដែលខ្ញុំចុះទៅជួបសំណេះសំណាល ឬក៏អប់រំ ឬក៏ទៅចូលរួមការងារគឺខ្ញុំតែងដោះស្រាយ

ជីវភាព។ ឧទាហរណ៍៖ ដូចជាសត្វ ធ្វើម្ហូប ជាសត្វគោក្តី ជាសត្វជ្រូកក្តី ជាមាន់ទាក្តី គឺខ្ញុំតែងតែឲ្យ ឧបត្ថម្ភតែពេលខ្ញុំទៅ គឺខ្ញុំជួយឧបត្ថម្ភ ខ្ញុំអាណិត។ ចាស នេះដែលខ្ញុំថាអំពើល្អរបស់ខ្ញុំ។

[១០:៤១:៤៩]

**ស៖** ជាការសួរបន្តទៅនឹងអ្វីដែលលោកស្រីបាននិយាយ។ នៅក្នុងចម្លើយរបស់លោកស្រីជា-មួយសហចៅក្រមស៊ើបអង្កេត សំណួរ១៤១ លោកស្រីបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "មានការបោះឆ្នោតជ្រើសរើសប្រធានសហករណ៍នៅក្នុងភូមិ ដែលរកអ្នកណាដែលល្អនៅក្នុងភូមិ។ បន្ទាប់ពីប្រជាជនក្នុងភូមិយល់ព្រមហើយ ទើបខ្ញុំតែងតាំង។ ខ្ញុំមានសិទ្ធិដកចេញប្រធានសហករណ៍ណាដែលមិនល្អ ស៊ីលើស ស៊ីខ្វះអី។ បន្ទាប់មក ជ្រើសរើសប្រធានសហករណ៍ថ្មីចេញពីប្រជាជនធម្មតាដែរ"។ តើលោកស្រីអាចផ្តល់ឧទាហរណ៍បានដែរឬទេ ថាតើប្រធានសហករណ៍ដែលមិនល្អ ដែលស៊ីលើស ស៊ីខ្វះហ្នឹង តើជាមនុស្សបែបណាដែរ ដែលលោកស្រីដកចេញនោះ?

**ឆ៖** ចាស សូមជម្រាបថា ប្រជាជនដែល មេប្រធានសហករណ៍ មិនមែនប្រជាជនធម្មតាទេ។ ដែលហៅថា ហូបលើស ហូបខ្វះ លួចលាក់ជាម្ហូបអាហារនៅក្នុងសហករណ៍ភូមិរបស់ខ្លួនហ្នឹង ហ្នឹងដែលខ្ញុំកំណត់ថាមនុស្សមិនល្អ ហើយដកចេញៗប្តូរដាក់អ្នកផ្សេងទៀតចាស។

**ស៖** តើលោកស្រីចាំទេថា តើមានភស្តុតាងច្បាស់លាស់ដែលថា លោកស្រីដកកម្មាភិបាលញ្ញ ឬក៏ដកប្រធានសហករណ៍ចេញដោយសារតែអំពើ ឬក៏អាកប្បកិរិយាមិនល្អ។ លោកស្រីមានភស្តុតាងច្បាស់លាស់ទេ?

**ឆ៖** ទេ វាមានច្រើន ខ្ញុំអាចមិនចាំបានទាំងអស់ទេ។

[១០:៤៤:២០]

**ស៖** ខ្ញុំយល់ថាលោកស្រីពិបាកក្នុងការចាំឈ្មោះមនុស្ស ប៉ុន្តែលោកស្រីអាចចាំអំពីសកម្មភាពរបស់កម្មាភិបាលដែលធ្វើឲ្យលោកស្រីសម្រេចចិត្តដកចេញដោយសារតែកម្មាភិបាលនោះជាមនុស្សល្អ។ លោកស្រីចាំទេ?

**ឆ៖** ដូចជាមិនបានចាំ វាច្រើនពេកភ្លេចអស់។

**ស៖** មិនអីទេលោកស្រី។ ឥឡូវនេះខ្ញុំចង់សួរអំពីកម្មាភិបាលស្រុក១០៥ម្នាក់ទៀត ហើយខ្ញុំសួរថា -- ហើយខ្ញុំនឹងសួរលោកស្រីចាំគាត់ឬក៏អត់។ បុគ្គលនេះឈ្មោះ ពេជ្រ ជឹម តើលោកស្រីចាំអ្វីខ្លះអំពីឈ្មោះ ពេជ្រ ជឹម នេះ?

**ឆ៖** ចាស ខ្ញុំស្គាល់ ពេជ្រ ជឹម។ តែខ្ញុំមិនមានចាំអ្វីក្រៅពីការស្គាល់ទេ។

**ស៖** តើលោកស្រីចាំអំពីគោលជំហរនយោបាយរបស់គាត់ ឬក៏អំពីគំនិតនិងទស្សនៈរបស់គាត់ ព្រមទាំងសកម្មភាពរបស់គាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** ចាស ខ្ញុំមិនចាំបានទេ ហើយគ្រាន់តែស្គាល់ ហើយគាត់ដូចថាមើលទៅជាគំនិតរបស់គាត់ គាត់ជាមនុស្សស្លូតបូតដែរ តែប៉ុណ្ណឹង គាត់អត់អ្នកកាចចសាហាវអីទេ ស្គាល់តែប៉ុណ្ណឹង។

**ស៖** តើគាត់ជាមនុស្សល្អ ឬក៏ថាជាមនុស្សស មនុស្សខ្មៅអី ដូចលោកស្រីដែរឬទេ?

**ឆ៖** ខ្ញុំស្គាល់ថាគាត់ស្លូតត្រង់ គាត់អត់មានអីឃោរឃៅអីទេ។ នេះតាមការដែលខ្ញុំស្គាល់។

[១០:៤៧:១៣]

**ស៖** ខ្ញុំនឹងសួរ ពេជ្រ ជឹម នៅពេលបន្តិចទៀត ប៉ុន្តែឥឡូវនេះខ្ញុំចង់សួរពីបុគ្គលម្នាក់ទៀតឈ្មោះ សោម។ លោកស្រីបាននិយាយអំពីគាត់ប្រាប់អ្នកស៊ើបអង្កេត គឺនៅត្រង់សំណួរ៥៨ នៃចម្លើយរបស់លោកស្រី ហើយខ្ញុំនឹងអាន "សំណួរ៖ គឺថានៅពេលនោះតើអ្នកណាជាគណៈតំបន់១៣?" ហើយលោកស្រីឆ្លើយថា៖ "មុនដំបូងគេគឺ តាមុត និង ពូសោម ជាគណៈតំបន់១៣។ ពូសោម ប្រហែលជាលេខាតំបន់១៣ ព្រោះភាគច្រើននៅក្នុងការប្រជុំ ពូសោម ជាអ្នកឡើងនិយាយ និងជាអ្នកសម្រេច"។ តើលោកស្រីចាំថាលោកស្រីផ្តល់ចម្លើយនេះទៅអ្នកស៊ើបអង្កេតនៅការិយាលសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**ឆ៖** ចាស ខ្ញុំបានផ្តល់មែន។

**ស៖** តើលោកស្រីចាំអ្វីបន្ថែមទៀតទេ ទាក់ទងទៅនឹង ពូសោម?

**ឆ៖** ខ្ញុំអត់បានចាំទៀតទេចាស ព្រោះវាយូរហើយ។

**ស៖** ហើយខ្ញុំយល់អំពីបញ្ហានេះលោកស្រី។ ឥឡូវនេះខ្ញុំចង់អាននូវសម្រង់មួយទៀតពីក្នុង ឯកសារ E3/11682, អង់គ្លេសមានលេខ 00819074 ដល់ 5, បារាំងមានលេខ 00842928 និងខ្មែរមានលេខ 00013961 ដែលនេះជាចម្លើយសារភាពរបស់ ជូ ជេត។ ប្រហែលជាគាត់ផ្តល់នៅពេលដែលគាត់ជាប់ឃុំនៅ ស-២១ ហើយខ្ញុំចង់អាននូវឃ្លាឲ្យលោកស្រីស្តាប់។

[១០:៤៩:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំរកឯកសារហ្នឹងមិនឃើញទេ នៅក្នុងបញ្ជីដែលផ្ដល់ឲ្យកាលពីសប្ដាហ៍មុនក៏មិនឃើញ នៅក្នុងអ៊ីនធីហ្វេស ក៏អត់ឃើញដែរ។ អ៊ីចឹង ខ្ញុំសូមឆ្លល់ដែរ អំពីឆន្ទៈរបស់ភាគីការពារក្ដី ដែលចង់ឲ្យអង្គជំនុំជម្រះភ្ញាក់ផ្អើលនិងភាគីទាំងអស់ ហើយជាពិសេសហ្នឹងគឺថាដកស្រង់សម្រង់មួយដែលជាចម្លើយសារភាពហ្នឹង ខ្ញុំមិនដឹងថាជាចម្លើយសារភាពណាមួយនោះទេ ពីព្រោះថា ជូជេត ប្រហែលទំនងជាបាននិយាយឆ្លើយទាំងអស់នេះក្រោមទារុណកម្ម។ អ៊ីចឹងគឺជាដកស្រង់ពីអ្វីដែលអ្នកសួរចម្លើយបានរៀបរាប់ អ៊ីចឹងត្រូវតែគោរពគោលការណ៍ ព្រោះថាគោលការណ៍ត្រូវសួរតទល់គ្នា។ ឯកសារទាំងអស់នេះមិនបានផ្ដល់ជូនភាគី ហើយឥឡូវនេះ យើងកំពុងតែនៅចំពោះមុខការដកស្រង់មួយដែលធ្វើឲ្យយើងភ្ញាក់ផ្អើល ព្រោះថាដើម្បីឲ្យគោរពភាគីទាំងអស់ហ្នឹងត្រូវតែមាន អនុញ្ញាតឲ្យមានការតទល់គ្នា។ អ៊ីចឹង ខ្ញុំសូមជំទាស់ការប្រើប្រាស់ឯកសារនេះឥឡូវនេះ ហើយសុំឲ្យគាត់ដាក់សំណើឲ្យត្រឹមត្រូវ។

**លោក វិចទ័រ កូប៉េ៖**

លោកប្រធាន ព្រះរាជអាជ្ញាគាត់និយាយត្រូវ ហើយខ្ញុំសូមអភ័យទោស ដែលថាខ្ញុំមិនបានដាក់នៅក្នុងអ៊ីនធីហ្វេស។ ដូច្នេះ ខ្ញុំស្នើសុំថាខ្ញុំទុកសួរសំណួរនេះក្រោយពីឈប់សម្រាកអាហារថ្ងៃត្រង់វិញ ដើម្បីឲ្យភាគី ក៏ដូចជាអង្គជំនុំជម្រះបានសិក្សាទៅលើឯកសារនេះ ដូចដែលយើងបានពិភាក្សាក្នុងសប្ដាហ៍កន្លងមក និងកន្លងមកមួយទៀត ហើយគឺថាព្រះរាជអាជ្ញាគាត់ដឹងអំពីឯកសារ ប៉ុន្តែប្រហែលជាមានបញ្ហាអ្វីមួយកើតឡើង ដោយសារខ្ញុំមិនបានដាក់នៅក្នុងអ៊ីនធីហ្វេស។ ដូច្នេះ ខ្ញុំយល់ស្រប ខ្ញុំអាចលើកសំណួរនេះទៅសួរនៅក្រោយពេលឈប់សម្រាកអាហារថ្ងៃត្រង់។ អង្គជំនុំជម្រះសម្រេចយ៉ាងណា?

[១០:៥២:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៦:៣៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ លោក មេធាវី កូប៉េ អង្គជំនុំជម្រះសុំឲ្យលោកជួយបំភ្លឺដើម្បី

ឱ្យយល់ច្បាស់ថា តើលោកមានយល់ពីគោលបំណងរបស់លោក តើលោកមានគោលបំណងចង់អានខ្លឹមសារនៃចម្លើយសារភាពរបស់លោក ជួ ជេត ដែលគាត់បានឆ្លើយនូវមន្ទីរស-២១ ដែរឬទេ? ឬក៏លោកចង់អានចំណារដែលមាននៅក្នុងចម្លើយសារភាពនេះ។ ហើយសំណួរទី២របស់ខ្ញុំ គឺទាក់ទងទៅនឹងភាពពាក់ព័ន្ធនៃសំណួររបស់លោក ឬក៏ការអានរបស់លោកពីព្រោះថាកាលពីព្រឹកមិញនេះលោកបានចោទសំណួរទៅសាក្សីទាក់ទងទៅនឹង ជួ ជេត រួចទៅហើយ ហើយនិងអត្ថិភាពនៃទំនាក់ទំនងរវាង ជួ ជេត ហើយនិងកម្មាភិបាលស្រុកត្រាំកក់ ហើយសាក្សីបានឆ្លើយប្រាប់លោកហើយថា គាត់មិនដឹងអីទេ សាក្សីឆ្លើយព្រឹកមិញហើយៗ។

**លោក វ៉ិចទ័រ កូប៉េ៖**

ចៅក្រមឡាវែន៍ ខ្ញុំអាចឆ្លើយទៅនឹងសំណួរទាំងពីរ។ ចេតនារបស់ខ្ញុំគឺ ចង់អាននូវមួយឃ្លាចេញពីចម្លើយសារភាពរបស់គាត់ ដែលនេះគឺជាផ្នែកមួយដែលគាត់រៀបរាប់អំពីគោលជំហរនយោបាយរបស់ឈ្មោះ សោម ហើយគាត់បាននិយាយថា សោម ជាមនុស្សដែលតឹងរ៉ឹងនៅក្នុងនេះ។ ដូច្នេះនេះគឺជាផ្នែកដែលខ្ញុំចង់អានឱ្យសាក្សីស្ដាប់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើនេះគឺថា មិនមែនជាប្រធានបទតែមួយដែលបានលើកឡើងកាលព្រឹកមិញទាក់ទងទៅនឹងសំណួរដែលលោកបានសួរកាលព្រឹកមិញទៅសាក្សីឬ? អ៊ីចឹង ខ្ញុំសួរថា ភាពពាក់ព័ន្ធនៅត្រង់ណាដែរ ពីព្រោះថាខ្ញុំមើលទៅឃើញថា លោកស្រីសាក្សីបានឆ្លើយនឹងសំណួរនេះហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំចង់សួរគាត់អំពីចម្លើយរបស់ សោម ដែលថា សោម ជាមនុស្សដែលគាបសង្កត់គេខ្លាំង។ ដូច្នេះ ខ្ញុំចង់ដឹងអំពីចម្លើយតទល់របស់លោកស្រី។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ៊ីចឹង ខ្ញុំសួរថាៗ ភាពពាក់ព័ន្ធនៅត្រង់ណាដែរ បើសាក្សីនោះ គាត់ឆ្លើយថាគាត់អត់មានស្គាល់ដឹងពីទំនាក់ទំនងអ្វីទេ។ អ៊ីចឹងលោកចង់សួរថាតើលោកស្រីសាក្សីហ្នឹងគាត់បានឃើញគេធ្វើទារុណកម្ម ជួ ជេត នៅមន្ទីរស-២១ ឬក៏យ៉ាងណា?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនចង់សួរអំពីទំនាក់ទំនងរវាង ជួ ជេត និងសោម ទេ ខ្ញុំគ្រាន់តែចង់សួរគាត់អំពីអ្វីដែល ជួ

ជេត និយាយនៅស-២១ថា ជូ ជេត ជាមនុស្សជិះជាន់ ជាមនុស្សឆ្វេងនិយម ជាមនុស្សដែលចូលចិត្ត ដែលថាអនុវត្តបដិវត្តន៍វប្បធម៌ជាដើម។ ខ្ញុំគ្រាន់តែចង់សួរគាត់អំពីបញ្ហានេះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០០:២១]

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ អង្គជំនុំជម្រះសូមជម្រាបលោកថា សំណួរទាំងឡាយណាដែលដកស្រង់នូវខ្លឹមសារនៃកំណត់ហេតុដែលបានមកពីការធ្វើទារុណកម្ម អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យតាំង -- ឲ្យភាគីឲ្យលោកនិងភាគីដទៃទៀត តាំងសំណួរឡើយ ហើយយើងបានជម្រាបហើយថា បញ្ហានេះគឺលោកបានសួរកាលពីលើកមុនរួចហើយ ហើយអង្គជំនុំជម្រះកំពុងតែរៀបចំនូវសេចក្ដីសម្រេចឆ្លើយតបនឹងសំណើសុំរបស់លោក ដែលនឹងអាចចេញនៅក្នុងសប្ដាហ៍ក្រោយនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំរំពឹងរង់ចាំនូវសេចក្ដីសម្រេចបែបនោះ។ ប៉ុន្តែខ្ញុំសូមកត់សម្គាល់ផងដែរ ថាការស៊ើបអង្កេតបឋមបានបង្ហាញថា មិនមានភស្តុតាងមួយក្រឡេកភ្នែកណាមួយបង្ហាញថា ជូ ជេត ត្រូវទទួលរងទារុណកម្មនោះឡើយ។ ហើយកាលពីម្សិលមិញ ព្រះរាជអាជ្ញាក៏គាត់បានអានអំពីភស្តុតាងមួយដែលថាមិនមានការធ្វើទារុណកម្មផងដែរ។ ដូច្នេះ ខ្ញុំគ្រាន់តែចង់សួរសំណួរជាក់លាក់មួយនេះទៅលើសាក្សីអំពីអាកប្បកិរិយា និងគោលជំហរនយោបាយរបស់ឈ្មោះ សោម តែប៉ុណ្ណោះ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំនឹងបន្តទៅមុខទៀត ទៅប្រធានបទថ្មីមួយទៀត។

[១១:០២:០០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី នៅព្រឹកនេះ លោកស្រីនិយាយដោយត្រួតៗអំពីហេតុការណ៍នេះហើយ គឺពាក់ព័ន្ធទៅនឹងសំណួររបស់ចៅក្រម ឡាវែន់ អំពីបុគ្គលម្នាក់ឈ្មោះ សៅ វ៉ន ហៅ សៅ ពត។ ហើយនៅព្រឹកនេះ លោកស្រីបានផ្ដល់សក្ខីកម្មថាលោកស្រីមិនចាំច្បាស់អំពីបុគ្គលម្នាក់នេះទេ។ លោកស្រីនិយាយថាគាត់ទទួលខុសត្រូវលើឃុំ ប៉ុន្តែគាត់ -- លោកស្រីមិនដឹងអំពីតួនាទីរបស់គាត់ទេ។ លោកស្រីនិយាយថាគាត់ទទួលខុសត្រូវក្នុងពេលវេលាជាមួយដូចលោកស្រីដែរ ប៉ុន្តែលោកស្រីមិនដឹងថាតើតួនាទីគាត់ចប់នៅពេលណានោះទេ គ្រាន់តែថាលោកស្រី ហើយនិងគាត់ធ្វើការជាមួយគ្នាអស់រយៈពេលយូរ។

ហើយតាមដែលខ្ញុំដឹងទៅលើសក្ខីកម្មរបស់លោកស្រីនៅព្រឹកនេះ ឥឡូវនេះ ខ្ញុំចង់អាននូវសម្រង់មួយមកពីចម្លើយរបស់គាត់ប្រាប់អ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មកខ្ញុំនឹងសួរឲ្យលោកស្រីរំឭកទៅលើអ្វីដែលបានកើតឡើង។ លោកប្រធាន ខ្ញុំយោងទៅលើឯកសារ E127/7.1.8 អង់គ្លេសមានលេខ 00901568, ខ្មែរមានលេខ 00893275, បារាំង 00778647។

អ្នកស៊ើបអង្កេតបានសួរ សៅ វ៉ន នូវសំណួរដូចតទៅនេះ “មុនរបបខ្មែរក្រហម ថ្ងៃ១៧ មេសា ៧៥ តើលោករស់នៅទីណា? និងលោកធ្វើអ្វី?” ហើយ សៅ វ៉ន ហៅ សៅ ពត បានឆ្លើយដូចតទៅនេះ “ចម្លើយទី១៖ មុនឆ្នាំ៧៥ ខ្ញុំដាក់ -- ខ្ញុំធ្វើស្រែនៅឃុំស្រែគ្រូ។ ខ្ញុំមិនមានតួនាទីរដ្ឋបាលអីទេ។ បន្ទាប់ពីរដ្ឋប្រហារឆ្នាំ៧០ ខ្ញុំរៀបការជាមួយនារីម្នាក់ នៅឃុំជាងទង ហើយក្រោយមកទៀត ខ្ញុំដូរទៅនៅជាមួយប្រពន្ធរបស់ខ្ញុំនៅត្រពាំងទឹក ដោយសារខ្ញុំជាអតីតសិស្ស គេចាត់តាំងឲ្យខ្ញុំធ្វើជាប្រធានភូមិត្រពាំងទឹក។ នៅថ្ងៃ១ មករា ឆ្នាំ៧១ ខ្ញុំធ្វើការនៅក្នុងគណៈកម្មាធិការអប់រំ នៅក្នុងឃុំពពេល។ ខ្ញុំចង់បញ្ជាក់ច្បាស់ថា នៅក្នុងឃុំជាងទង ត្រូវបានរំដោះនៅពេលនោះ ហើយខ្មែរក្រហមចាត់តាំងឲ្យខ្ញុំធ្វើជាមេឃុំ។ បន្ទាប់ពីថ្ងៃ១៧ មេសា ៧៥ គេចាត់តាំងឲ្យខ្ញុំធ្វើជាគណៈឃុំកំពង់ស្វាយ នៅក្នុងតំបន់២៥ នៃភូមិភាគនិរតី”។ លោកស្រីសាក្សី លោកស្រីបានស្ដាប់ចម្លើយរបស់ សៅ វ៉ន ដែលឆ្លើយទៅនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហើយ។ ថាតើអ្វីដែលខ្ញុំអានហ្នឹងធ្វើឲ្យលោកស្រីនឹកឃើញអំពីឈ្មោះ សៅ វ៉ន នេះដែរឬទេ?

[១១:០៥:៤៥]

**ប្រធានអង្គជំនុំ៖**

លោកស្រី ខឹម បឿន ឆ្លើយតបនឹងសំណួរ។ លោកស្រីស្ដាប់បានទេ?

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស ស្ដាប់បាន។ ខ្ញុំសូមឆ្លើយថា ខ្ញុំនឹកឃើញគាត់ដកចេញ តែខ្ញុំមិនចាំថ្ងៃខែឆ្នាំ ទើបតែគាត់រំឭកនេះឯង។

**ស៖** អ្វីដែលខ្ញុំអានឲ្យលោកស្រីស្ដាប់ តើវាត្រឹមត្រូវដែរឬទេ? ដែលថា តើលោកស្រីចាំទេថា គាត់មានតួនាទីដូចដែលខ្ញុំអានឲ្យលោកស្រីស្ដាប់ហ្នឹងអ៊ីចឹងទេ?

**ឆ៖** ចាស ខ្ញុំអត់ច្បាស់ ខ្ញុំចង់សុំម្ដងទៀត ព្រោះខ្ញុំវាថ្លង់ស្ដាប់អត់សូវបានទេ។

**ស៖** ខ្ញុំអាននូវចម្លើយប្រាប់លោកស្រី ហើយគាត់និយាយថាគាត់មានតួនាទីណាមួយ។ ដូច្នេះ ខ្ញុំ

ចង់ដឹងថាតើលោកស្រីចាំទេថា សៅ វ៉ន និយាយអំពីតួនាទីរបស់គាត់នោះវាត្រឹមត្រូវដែរឬក៏អត់?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ជាពិសេសនោះ គាត់និយាយអំពីការងាររបស់គាត់នៅគណៈអប់រំឃុំពពេល គណៈអប់រំប្រជាជននៅឃុំពពេល។ តើលោកស្រីចាំទេ ថាប្ដីរបស់លោកស្រីស្គាល់ សៅ វ៉ន ហ្នឹងដែរឬទេ?

**ឆ៖** ចាស ស្គាល់ តែខ្ញុំអត់ក្ដាប់បានថា គាត់ទៅធ្វើនៅឃុំពពេលទេ អត់ដឹងទេ។

**ស៖** ហើយសំណួរចុងក្រោយរបស់ខ្ញុំ គឺថាក្រោយពីអានអំពីប្រវត្តិរូបរបស់គាត់ តើវាធ្វើឱ្យលោកស្រីនឹកឃើញដែរឬទេ? តើធ្វើឱ្យលោកស្រីដឹងអំពីគោលនយោបាយ ឬក៏គោលជំហររបស់ សៅ វ៉ន ហ្នឹងដែរឬទេ?

**ឆ៖** ចាស ខ្ញុំស្គាល់ ធ្លាប់ធ្វើការជាមួយគ្នា តែខ្ញុំអត់ដឹងថា ទៅធ្វើឃុំពពេលទេ។ អត់មានដឹងថាធ្វើឃុំពពេលទេ។

[១១:០៨:៥៥]

**ស៖** មិនអ្វីទេលោកស្រី ប៉ុន្តែឥឡូវនេះខ្ញុំចង់អានឱ្យលោកស្រីស្ដាប់នូវសម្រង់មួយដ៏វែង គឺសម្រង់នៃសក្ខីកម្មរបស់ ពេជ្រ ជឹម ប្រហែលជាមួយសប្ដាហ៍កន្លងមក មួយសប្ដាហ៍ជាងកន្លងមក។ ខ្ញុំនឹងអានឱ្យលោកស្រីស្ដាប់។ ប្រហែលជាមួយនាទី ឬក៏ពីរនាទី ខ្ញុំអានដោយយឺតៗ។ ខ្ញុំបានឱ្យអ្នកបកប្រែនូវឯកសារហ្នឹងហើយ ប្រហែលជាគេអាចសួរបាន -- អាចស្ដាប់បាន។ ដូច្នេះ ខ្ញុំចង់ឱ្យលោកស្រីស្ដាប់បន្ទាប់មកសួរសំណួរ តើលោកស្រីយល់អំពីអ្វីដែលខ្ញុំប្រុងធ្វើដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកស្រី ខឹម បឿន ឆ្លើយតប លោកស្រី ខឹម បឿន!

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស ស្ដាប់អត់បាន ចង់ -- គាត់មានយោបល់ ខ្ញុំស្ដាប់អត់បានអំមិញ ចង់និយាយពីម៉េច?

**សួរដោយលោក រ៉ិចឆ័រ កូប៉េ៖**

**ស៖** ខ្ញុំមិនទាន់សួរសំណួរទេ ប៉ុន្តែខ្ញុំគ្រាន់តែប្រាប់លោកស្រីថា ខ្ញុំនឹងអាននូវសម្រង់មួយចំនួនចេញពីសក្ខីកម្មរបស់ ពេជ្រ ជឹម ដែលសម្រង់ហ្នឹងប្រហែលជាមានពេលវេលា ចំណាយពេលវេលាអស់១០នាទី។ តើលោកស្រីយល់ដែរឬទេ?

**ឆ៖** ចាស។

**សៈ** លោកប្រធាន ក៏ដូចជាភាគីទាំងអស់ នេះគឺឯកសារ E1/292.1 ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១៥ គឺចាប់ផ្ដើមនៅពេលម៉ោង០៩:៣៧ ហើយវាបញ្ចប់នៅនាទី ម៉ោង១០:០៤នាទី។ ខ្ញុំនឹងដកស្រង់នូវសម្រង់មួយចំនួន ហើយខ្ញុំចង់ឲ្យលោកស្រីគាត់ឆ្លើយតបទៅនឹងចំណុចទាំងអស់នេះ។ លោកស្រីសាក្សីជាការចាប់ផ្ដើមខ្ញុំបានដាក់នូវសក្ខីកម្មរបស់ សៅ វ៉ន ហើយសួរលោក ពេជ្រ ជឹម អំពីមតិយោបល់របស់គាត់ ដូច្នេះខ្ញុំសូមចាប់ផ្ដើមអាន។ ខ្ញុំសូមចាប់ផ្ដើមនៅម៉ោង០៩:៣៧:៥០វិនាទី។ ដូច្នេះសំណួរលោក ពេជ្រ ជឹម ចំពោះកម្មាភិបាលនេះគឺសំណួរទី៥ ក្នុងនាមជាមេឃុំកំពង់ស្វាយ "តើលោកបានទទួលបញ្ជាពីថ្នាក់លើឲ្យចាប់ខ្លួនដែរឬទេ?" សូមបញ្ចប់ការដកស្រង់។ ឆ្លើយ៖ "ក្នុងនាមជាគណៈឃុំកំពង់ស្វាយ ខ្ញុំមិនចង់បង្កគ្រោះថ្នាក់ដល់ប្រជាជនណាម្នាក់ដែលធ្វើខុសនោះទេ ប៉ុន្តែកម្រិតឃុំគឺមានសិទ្ធិរាយការណ៍ទៅថ្នាក់លើ។ ខ្ញុំមានសិទ្ធិក្នុងការរាយការណ៍ទៅថ្នាក់។ ឧទាហរណ៍នៅពេលដែលប្រជាជនមិនមានស្រូវហូបគ្រប់គ្រាន់ ឬក៏នៅពេលដែលប្រជាជនធ្វើស្រែបានត្រឹម២តោនក្នុង១ហិកតា។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ តាម៉ុក បានចេញបញ្ជាថា ឃុំ ស្រុក និងតំបន់ មិនមានសិទ្ធិអំណាចក្នុងការចាប់ខ្លួន ឬក៏សម្លាប់ប្រជាជនឡើយ។ សំណួរ៖ តើកម្រិតត្រឹមណាដែលកម្រិតឃុំមានសិទ្ធិរាយការណ៍ទៅ? ចម្លើយ៖ កម្រិតឃុំមានសិទ្ធិរាយការណ៍ទៅកម្រិតស្រុក ប៉ុន្តែដើម្បីធ្វើការ -- ដើម្បីធ្វើរបាយការណ៍អំពីមនុស្សម្នាក់ គណៈឃុំដែលមានសមាជិកប្រាំទៅប្រាំពីររូប ត្រូវតែធ្វើការប្រជុំដើម្បីមានការឯកភាពគ្នា មុនពេលនឹងរាយការណ៍ទៅកម្រិតស្រុក ទៅថ្នាក់ស្រុក។ សំណួរ៖ តាម៉ុក បាននិយាយថាថ្នាក់ស្រុក និងថ្នាក់តំបន់មិនមានសិទ្ធិអំណាចសម្លាប់ប្រជាជនទេ។ ហេតុអ្វីបានជាមានប្រជាជនជាច្រើនត្រូវបានគេសម្លាប់នៅក្នុងស្រុក និងនៅតំបន់? ក្នុងចម្លើយរបស់គាត់ គាត់ឆ្លើយថា៖ ខ្ញុំមិនដឹងអំពីការអនុវត្តនោះទេ ប៉ុន្តែខ្ញុំចាំអំពីការណែនាំរបស់ តាម៉ុក យ៉ាងច្បាស់។ សំណួរ៖ តើ តាម៉ុក នៅក្នុងគណៈភូមិភាគដែរឬទេ? ចម្លើយ៖ បាទ។ នេះគឺជាចម្លើយរបស់ សៅ វ៉ន"។

[១១:១៥:០៨]

លោកស្រីបន្ទាប់មកទៀត ខ្ញុំប្រាប់លោក ពេជ្រ ជឹម ថាផ្នែកដែល -- នេះគឺជាផ្នែកដ៏សំខាន់របស់ សៅ វ៉ន ហើយខ្ញុំសូមដកស្រង់៖ "តើនៅពេលដែល តាម៉ុក ធ្វើការប្រកាសបែបនេះ?" ចម្លើយរបស់ សៅ វ៉ន៖ "តាម៉ុក ធ្វើការប្រកាសនេះតាំងពីមុនឆ្នាំ៧៥ ក្នុងពេលកិច្ចប្រជុំបិទដែលធ្វើឡើងជារៀងរាល់ឆ្នាំនៅក្នុងព្រៃដែលចូលរួមដោយគណៈឃុំ គណៈស្រុក គណៈខេត្ត ហើយនិងខាងភូមិភាគ -- ខាងវរសេនាធំ។ បន្ទាប់ពីឆ្នាំ៧៥ គឺមានការប្រជុំមួយទៀតនៅក្នុងទីរួមខេត្តតាកែវ ដែលមានវត្តមានរបស់

តាម៉ុក ហើយនិង សោម ដែលស្ថិតនៅក្នុងគណៈតំបន់១៣ ដែលប្រកាសថាទាហានដែលមានឋានៈចាប់ពីវរសេនីយ៍ -- ចាប់ពីស័ក្តិ១រហូតដល់ស័ក្តិ៥ មិនត្រូវបានគេធ្វើបាបនោះឡើយ។ អ៊ីចឹងលោកមានន័យថា អ្នកដែលមានឋានៈចាប់ពីស័ក្តិមួយ ដល់ស័ក្តិបីអត់ចាប់ទេឬ? គឺលោកឆ្លើយថា "ខ្ញុំមិនដឹងទេ ព្រោះថាការអនុវត្ត វាប្រែប្រួលពីតំបន់ តាមតំបន់"។ នេះគឺជាសម្រង់ចេញពីចម្លើយរបស់ សៅ វ៉ន ខ្ញុំសួរទៅពេជ្រ ជឹម។ ហើយលោក ពេជ្រ ជឹម បានឆ្លើយដូចតទៅនេះ គឺមុនម៉ោង ០៩:៤៣ បន្តិច លោក ពេជ្រ ជឹម គាត់បានឆ្លើយ "ខ្ញុំបានចូលរួមប្រជុំហ្នឹង ក្រោយឆ្នាំ៧៥ប៉ុណ្ណោះ គឺនៅក្រោយមន្ទីរបក្សដែល តាម៉ុក បានចូលរួម ហើយកិច្ចប្រជុំនៅត្រូវបានធ្វើនៅក្នុង -- ហើយកិច្ចប្រជុំដែលធ្វើនៅព្រៃ ខ្ញុំមិនបានចូលរួមទេ ប្រហែលជា ខុម បានចូលរួមនៅក្នុងប្រជុំនោះ។ ដូច្នេះ វាពិបាកក្នុងការកោះអញ្ជើញសមាជិកទាំងអស់ឲ្យចូលការប្រជុំ"។ ខ្ញុំសួរទៅ ពេជ្រ ជឹម។ ខ្ញុំយល់ ដូច្នេះ ខ្ញុំនឹងផ្តោតទៅលើការប្រជុំទី២ នៅទីរួមខេត្តតាកែវ។ កម្មាភិបាលម្នាក់នេះ និយាយអំពីកិច្ចប្រជុំនៅក្រោយឆ្នាំ៧៥។

[១១:១៦:១៧]

ហើយចម្លើយរបស់គាត់ "នៅតាកែវ ក្រោយរំដោះ ដូចច្រឡំទៀត តាមមើលនៅតាកែវ ក្រោយរំដោះ គឺមិនមែនមុនទេ ក្រោយ៧៥ ធ្វើនៅផ្ទះមាត់ទឹកខាងជើងក្រុង។ ធ្វើហ្នឹង រៀនសូត្រកងទ័ពទាំងអស់ ទ័ព ទាំងមេទ័ព ទាំងភូមិភាគទាំងអស់ចូលរួម។ ចម្លើយ៖ ការប្រជុំធ្វើឡើងនៅក្នុងខេត្តតាកែវក្រោយការប្រជុំនៅភ្នំពេញ"។ ហើយចុះក្រោមបន្តិច នៅនាទីម៉ោង ០៩:៤៦ "ប៉ុន្តែ តើលោកអះអាងដែរទេថា សេចក្តីប្រកាស ចម្លើយរបស់កម្មាភិបាលភូមិភាគនិរតី ដែលបានប្រាប់អ្នកស៊ើបអង្កេតថា តាម៉ុក បានប្រកាសថា ទាហានដែលមានឋានៈពីស័ក្តិ១ ដល់ស័ក្តិ៣ មិនត្រូវ -- ស័ក្តិ១ និងស័ក្តិ៥ នឹងមិនត្រូវប៉ះពាល់នោះទេ តើលោកអះអាងយ៉ាងណាចំពោះចម្លើយរបស់កម្មាភិបាលភូមិភាគនិរតីទេ? គាត់ឆ្លើយថា អ៊ីចឹងមែន"។ ប៉ុន្តែខ្ញុំអាចអះអាងថាចម្លើយដែលធ្វើនៅពេលនោះ ខ្ញុំសួរទៅ ពេជ្រ ជឹម បន្តទៀត "តើលោកចាំទេថា តើកម្មាភិបាលដទៃទៀតមកពីស្រុក១០៥ ចូលរួមនៅក្នុងកិច្ចប្រជុំនោះដែរឬទេ? ជាពិសេស តើលោកចាំដែរ ឬទេ ហឿន មានវត្តមាននៅក្នុងកិច្ចប្រជុំមួយនោះដែរឬទេ? ពេជ្រ ជឹម បានឆ្លើយថា បាទ គឺត្រឹមត្រូវហើយស្ត្រីនោះ។ ហឿន មានវត្តមាននៅក្នុងកិច្ចប្រជុំនៅតាកែវ"។ ហើយ ពេជ្រ ជឹម បានឆ្លើយបន្តទៀតថា៖ "ប្រហែលជា៥០ទៅ៦០នាក់ គឺមានអ្នកតំណាងមកពីយោធា មកពីមូលដ្ឋាន ប៉ុន្តែមិនមានអ្នកណាម្នាក់មកពីនាយកដ្ឋាននោះទេ ព្រោះ តាម៉ុក ចូលរួមក្នុងការផ្ទាល់ ចំពោះទាហាន គឺគេកោះប្រជុំមេទ័ពមកពីវរៈ ឬក៏មកពីកងពលធំឲ្យចូលរួម ហើយពួកគេបានអញ្ជើញទៅដល់ឃុំ និង

ស្រុក ប៉ុន្តែបញ្ជូនតែទៅឃុំមួយចំនួនប៉ុណ្ណោះ មិនមែនទាំងអស់នោះទេ។ ពួកគេមានឋានៈប្រហាក់ប្រហែលគ្នា ប៉ុន្តែពួកគេមានតួនាទីផ្សេងៗគ្នា។ ហេតុដូច្នេះហើយ ទើបឃុំមួយចំនួនចូលរួម ប៉ុន្តែឃុំមួយចំនួនទៀតអត់បានចូលរួម"។

[១១:១៨:៥១]

ខ្ញុំសូមផ្អាកបន្តិច ដោយសារតែខ្ញុំបានអានច្រើនណាស់ទៅហើយ។ ដូច្នេះសំណួរទី១ ដែលខ្ញុំចង់សួរលោកស្រី គឺថាតើលោកស្រីចាំដែរឬទេ ថាបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ គឺកិច្ចប្រជុំក្រោយថ្ងៃរំដោះ១៧ មេសា ៧៥ គឺកិច្ចប្រជុំនៅតាកែវ ដែល សៅ វ៉ន ហើយនិង ពេជ្រ ជឹម បានចូលរួម ហើយលោកស្រីក៏ប្រហែលជាបានចូលរួមដែរ តើលោកស្រីចាំដែរឬទេ?

**ឆ៖** ខ្ញុំដូចជាមិនបានចាំថាទៅប្រជុំទេ។ មិនបានចាំត្រង់ថាប្រកាសមេទាហានពីស័ក្តិ១ ដល់ស័ក្តិ៥ទៅ អនុគ្រោះ អត់មានទោស មានពៃរ៍អី ខ្ញុំអត់ ដូចអត់មានបានចូលរួមទេ។

**ស៖** គឺដូចជាមានចម្លើយមិនច្បាស់លាស់ពីរនៅក្នុងចម្លើយរបស់លោកស្រី តើលោកស្រីអាចឆ្លើយម្តងទៀតបានទេ?

**ឆ៖** ខ្ញុំអាចនឹកមិនឃើញក៏ថាបាន ព្រោះខ្ញុំនឹកមិនឃើញ។

**ស៖** អ៊ីចឹងលោកស្រីចង់និយាយថា លោកស្រីអត់ចាំពីការប្រជុំហ្នឹងទេមែនទេ?

**ឆ៖** ចាស ។

**ស៖** តើវាអាចដែរឬទេថា ដោយសារវាយូរមកហើយ ដែលថា ពេជ្រ ជឹម គាត់និយាយ ត្រឹមត្រូវថាលោកស្រីបានចូលរួមនៅក្នុងកិច្ចប្រជុំនៅតាកែវក្រោយថ្ងៃ១៧ មេសា ៧៥នោះ?

**ឆ៖** ខ្ញុំធ្លាប់បានប្រជុំមែន ប៉ុន្តែដូចអត់បានឮតាម៉ុក ប្រកាសអ៊ីចឹងទេ ព្រោះវាយូរហើយ ខ្ញុំក៏មិនបានចាំអស់ដែរ។ ប្រកាសរឿងទាហាន រឿងអីដូចមិនបាន។

**ស៖** ប៉ុន្តែ ទាំង សៅ វ៉ន ហើយនិង ពេជ្រ ជឹម បាននិយាយអំពីការប្រជុំពិសេសនៅខេត្តតាកែវ។ គាត់ក៏បានរៀបរាប់អំពីកន្លែងជាក់លាក់នៃការប្រជុំនោះផងដែរ។ លោកស្រីអាចរំឭកបានទេថាកិច្ចប្រជុំហ្នឹងកើតឡើងប្រហែលជានៅក្នុងខែឧសភា មិថុនា ឆ្នាំ៧៥ តើលោកស្រីចាំអំពីការប្រជុំបែបនេះទេ? តើលោកស្រីអាចនឹកឃើញដែរឬទេ?

**ឆ៖** ខ្ញុំអាចបានទៅចូលរួមប្រជុំ តែខ្ញុំអត់បានចាំពាក្យពេចន៍អីដែលលើកទេ។

[១១:២២:៣០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្បាងលេ៖**

បាទ សូមអរគុណលោកប្រធាន។ តាមពិតអម្បាញ់មិញនេះ ខ្ញុំឡើងចង់ឆ្លើយ ចង់និយាយថា សំណួរដដែលៗ ហើយចម្លើយគាត់ហ្នឹងច្បាស់ហើយ គ្រាន់តែអម្បាញ់មិញនេះ គាត់បានឆ្លើយមុនពេលខ្ញុំធ្វើអន្តរាគមន៍។ អ៊ីចឹងលោកប្រធាន អ៊ីចឹងអត់មានអ្វីនិយាយបន្តទៀតទេលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ឥឡូវនេះ ខ្ញុំសូមអានបន្តទៀតពីចម្លើយរបស់ ពេជ្រ ជឹម។ ខ្ញុំអានឲ្យលោកស្រីស្តាប់ លោកស្រីសាក្សី។ លោកប្រធានគឺឯកសារដដែលគឺនៅម៉ោង ០៩:៤៨នាទី។ ខ្ញុំសួរលោក ពេជ្រ ជឹម "តើលោកចាំទេថាមានមនុស្សប្រហែលប៉ុន្មាននាក់ចូលរួមនៅក្នុងកិច្ចប្រជុំនោះ? ពេជ្រ ជឹម បានឆ្លើយថា៖ ប្រហែលជា៥០ ទៅ៦០នាក់ គឺមានអ្នកតំណាងមកពីកងទ័ព មកពីមូលដ្ឋាន។ មន្ទីរមិនមានអ្នកមកទេ ព្រោះតាម៉ុក មកចូលរួមផ្ទាល់។ ចំពោះទាហាន គេអញ្ជើញមេទ័ពមកពីខាងវរសេនាធំ ឬក៏កងពល ហើយគេក៏អញ្ជើញចំពោះឃុំ និងស្រុក។ ប៉ុន្តែចំពោះឃុំមួយចំនួនប៉ុណ្ណោះ មិនមែនឃុំទាំងអស់ទេ។ គឺថាពួកគេមានឋានៈប្រហាក់ប្រហែលគ្នា ប៉ុន្តែគេមានតួនាទីផ្សេងៗគ្នា។ ហេតុដូច្នេះហើយ ទើបឃុំខ្លះចូលរួមហើយឃុំខ្លះទៀតមិនបានចូលរួម។

[១១:២៤:១៩]

ហើយខ្ញុំសួរសំណួរគាត់នៅម៉ោង ០៩:៥៤ "ខ្ញុំចង់សួរថាតើគាត់ចាំអ្នកណាផ្សេងទៀតដែលបានចូលរួមដែរឬទេ? ហើយគាត់និយាយថា ខ្ញុំចាំថា មានតែ តាម៉ុក, ពិន, សោម ហើយនៅថ្ងៃនោះ ខុម អត់មកទេ។ គាត់សុំទៅជួបគ្រួសាររបស់គាត់ ហើយខាងតំបន់គឺមានតំបន់១៣ ហើយខ្ញុំមិនចាំទេ។ មាស មុត មិននៅជិតនោះទេ ប៉ុន្តែ រ៉េន បានចូលរួម ហើយ រុន ក៏នៅទីនោះដែរ ហើយគាត់មានឈ្មោះហៅថា "០៥"។ ហើយសំណួរចុងក្រោយរបស់ខ្ញុំឈ្មោះចំពោះ ពេជ្រ ជឹម អំពីការប្រជុំនេះ គឺថាគឺនៅម៉ោង០៩:៥៦ លោកអះអាងថា "តាម៉ុក បាននិយាយ ហើយតាម៉ុក បានចេញបញ្ជាពាក់ព័ន្ធទៅនឹងមន្ត្រីមានបណ្តាស័ក្តិ។ តែ សោម មានបាននិយាយដែរទេ? ចម្លើយរបស់ ពេជ្រ ជឹម និយាយថា៖ នៅពេលដែល តាម៉ុក និយាយ សោម គាត់អត់ឡើងនិយាយទេ។ មានតែនៅពេលដែលតាម៉ុក មិននិយាយអ្វីទេ ទើប សោម អ្នកនិយាយ។ នេះគឺជាវិធាន និងជានីតិវិធីការងារ។ បើសិនបើមេនិយាយ អ្នកនៅក្រោម

បង្គាប់មិននិយាយទេ។ ដូច្នេះ សោម មិនបាននិយាយនៅពេលកិច្ចប្រជុំនោះទេ"។ ហើយខ្ញុំផ្តល់ព័ត៌មានលម្អិតបន្ថែមបន្តិចទៀត ទាក់ទងទៅនឹងចម្លើយរបស់ ពេជ្រ ជឹម អំពីប្រជុំនោះ។ ខ្ញុំដឹងថា វាកើតឡើងយូរឆ្នាំណាស់មកហើយ ថាតើអ្វីដែលខ្ញុំអាននេះ ធ្វើឱ្យលោកស្រីនឹកឃើញអ្វីខ្លះបន្ថែមដែរឬទេ?

**ឆៈ** ខ្ញុំអត់នឹកឃើញ។

[១១:២៦:២២]

**សៈ** សូមអរគុណលោកស្រី។ ខ្ញុំនៅសល់ពេលបីបួននាទីទៀត ហើយខ្ញុំនឹងសួរសំណួរអំពីបទល្មើសស្រាល និងបទល្មើសធ្ងន់។ លោកស្រីបានផ្តល់សក្ខីកម្មទៅអ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ សំណួរ១៥១, ១៥២។ នេះគឺជាសំណួរអំពីការរំលោភផ្លូវភេទ។ សំណួរគឺដូតទៅនេះ លោកស្រីនិយាយអំពីប្រភេទនៃបទល្មើសស្រាល និងបទល្មើសធ្ងន់។ បទល្មើសធ្ងន់មានការរំលោភសេពសន្ថវៈ។ ចំពោះទណ្ឌកម្ម តើអ្នករំលោភត្រូវគេដាក់ទណ្ឌកម្មដូចម្តេច? ហើយអ្នកចំពោះអ្នកដែលត្រូវគេចាប់រំលោភវិញ គេដាក់ទណ្ឌកម្មដូចម្តេច? អ្នកដែលរងគ្រោះពុំត្រូវបានគេដាក់ទណ្ឌកម្មទេ។ គេដាក់តែអ្នករំលោភគេប៉ុណ្ណោះ។ ពេលដែលយើងនិយាយពាក្យរំលោភ គឺជាការបង្ខំអ្នកណាម្នាក់រួមភេទដោយប្រើអំពើហិង្សា។ តើលោកស្រីចង់និយាយដូច្នេះមែនទេ? លោកស្រីឆ្លើយថា ចាស។ បើករណីដែលបុរសចាប់រំលោភស្ត្រី ហើយស្ត្រីនោះ មិនព្រម គឺបុរសនោះ នឹងត្រូវគេដាក់ទោស។ ចំណែកស្ត្រី គឺពុំដាក់ទោសនោះទេ"។ លោកស្រីសាក្សី តើលោកស្រីចាំថា លោកស្រីឆ្លើយនេះ ទៅឱ្យអ្នកស៊ើបអង្កេតដែរឬទេ?

**ឆៈ** ចាស ខ្ញុំបានឆ្លើយមែន។

**សៈ** តើលោកស្រីចាំដែរឬទេ ថានៅក្នុងឃុំរបស់លោកស្រី នៅពេលដែលលោកស្រីធ្វើជាមេឃុំ លោកស្រីធ្លាប់ដាក់ទណ្ឌកម្ម ឬក៏មានអ្នកធ្លាប់ទទួលទណ្ឌកម្មពីការរំលោភសេពសន្ថវៈនោះដែរឬទេ? តើលោកស្រីចាំអំពីឧទាហរណ៍នៃការដាក់ទណ្ឌកម្មនៅក្នុងឃុំលោកស្រីដែរឬទេ?

**ឆៈ** ចាស អត់មានទេ នៅឃុំខ្ញុំ តែគ្រាន់តែមានច្បាប់អ៊ីចឹង។

**សៈ** តើលោកស្រីដឹងដែរឬទេ ថាវិធាន ឬក៏ច្បាប់នេះ ត្រូវបានគេអនុវត្តជាមួយអ្នកដែលចាប់រំលោភនៅឃុំដទៃទៀតដែរឬទេ?

**ឆៈ** ចាស ខ្ញុំអត់យល់ទេ ចាស សុំម្តងទៀតមើល។

[១១:២៩:៣៣]

**ស៖** ខ្ញុំសួរលោកស្រីអំពីឧទាហរណ៍ អ្នកដែលគេដាក់ទណ្ឌកម្មនៅក្នុងឃុំរបស់លោកស្រី ចំពោះអ្នកដែលរំលោភគេ ហើយលោកស្រីក៏ឆ្លើយថាអត់មានទេ។ ប៉ុន្តែខ្ញុំចង់សួរអំពីឃុំដទៃទៀតនៅស្រុក ១០៥ តើមានការដាក់ទណ្ឌកម្មអ្នកដែលរំលោភគេដែរឬទេ?

**ឆ៖** ចាស អាចមាន។ មានដាក់ទណ្ឌកម្មចាស។ ទណ្ឌកម្មនោះក៏ខ្ញុំសូមជម្រាបគឺនៅឃុំពពេលដែលគេចាប់រំលោភហើយ គេចាប់មនុស្ស -- បុរសហ្នឹងដែលអ្នករំលោភគេហ្នឹងកោរសក់ កោរជាជើងក្អែកហើយ ហែតាំងពីឃុំពពេលដល់ឃុំជាងទងនេះឯង។ បានជាខ្ញុំដឹងចាស។

**ស៖** ខ្ញុំចង់និយាយអំពីឃុំរបស់លោកស្រីវិញ។ កាលពីម្សិលមិញយើងបាននិយាយអំពីគ្រួសារ គ្រួសាររបស់ មុំ ហឿន និងមាស គុណ តើលោកស្រីចាំអំពី មុំ ហឿន ដែរឬទេ? គឺ មុំ ហឿន ដែលជាប្តីរបស់ មាស សារ៉ាត់ នោះ?

**ឆ៖** ចាស ខ្ញុំស្គាល់។

**ស៖** តើលោកស្រីចាំអំពីការចោទប្រកាន់ចំពោះគាត់ គេចោទប្រកាន់ថាគាត់បានរំលោភប្រជាជនថ្មី គឺរំលោភនារីម្នាក់ឈ្មោះ ឃន នៅឃុំស្វាយចេក នៅស្វាយចេកដែរឬទេ?

**ឆ៖** ខ្ញុំអត់បានចាំ ប្រហែលជាភ្លេច។

[១១:៣២:០១]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថាប្រហែលជាដល់ពេលវេលាសម្រាប់ -- ល្អសម្រាប់ការឈប់សម្រាកហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ អញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការ។

លោកស្រី ខឹម ហឿន ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយសូមលោកស្រីសម្រាកចុះ ហើយអង្គ -- កិច្ចដំណើរការស្តាប់សក្ខីកម្មរបស់លោកស្រីនឹងចាប់ផ្តើមធ្វើជាបន្តនៅរសៀលនេះចាប់ផ្តើមពីម៉ោងមួយនិងសាមសិបនាទី។ សូមលោកស្រីរួមទាំងមេធាវីប្រឹក្សាសាក្សីមានវត្តមាននៅកន្លែងផ្តល់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ សូមជ្រាប។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារ ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ខឹម បឿន អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីនេះថា នៅក្នុងកិច្ចដំណើរការសវនាការចាប់ពីរសៀលថ្ងៃអង្គារទី០៥ ខែឧសភា ឆ្នាំ២០១៥ នេះតទៅរហូតដល់ចុងសប្តាហ៍ លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ គាត់មានធុរៈផ្ទាល់ខ្លួនចាំបាច់ គាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការបាន។ បន្ទាប់ពីយើងខ្ញុំបានពិគ្រោះជាមួយបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ម៉ាទីន ខារ៉ុបគីន ជាចៅក្រមបម្រុងអន្តរជាតិជំនួសកន្លែងចៅក្រម ក្លូឌា ហ្វេនស៍ រហូតដល់ពេលណាដែលលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ការអនុវត្តនេះដោយយោងតាមខ្លឹមសារនៃបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បាទ ជាបន្តទៅនេះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ខឹម បឿន។

[១៣:៣៥:៥៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោកស្រីសាក្សី ខ្ញុំមានសំណួរមួយចំនួនទៀតដើម្បីសួរទៅកាន់លោកស្រី តើលោកស្រីស្តាប់ឮខ្ញុំទេ?

**លោកស្រី ខឹម ឡឿន៖**

**ឆ៖** ចាសឮ។

**ស៖** លោកស្រីសាក្សី មុនពេលឈប់សម្រាកយើងបាននិយាយដោយសង្ខេបអំពីលោកស្រី អំពីពេជ្រ ជឹម យើងបាននិយាយថា លោកស្រីត្រូវបានគេចាត់ទុកជាកម្មាភិបាលបដិវត្តន៍មានចិត្តល្អ គួរឱ្យស្រឡាញ់។ តើលោកស្រីអាចជម្រាបយើងបានអ្វីខ្លះ អំពីសីលធម៌ទាំង១២ប្រការរបស់បក្សកុម្មុយនីស្តកម្ពុជា? តើលោកស្រីមាននៅចាំទេ អំពីសីលធម៌១២ប្រការនេះ?

**ឆ៖** ចាស ចាំអត់បានអស់។ ចាំអត់បានអស់ទេចាស។

[១៣:៣៧:២៧]

**ស៖** ខ្ញុំយល់ថាលោកស្រីមិនចាំសីលធម៌ទាំង១២ប្រការនេះទេ ក៏ប៉ុន្តែលោកស្រីចាំទេនៅចន្លោះឆ្នាំ៧៥ដល់៧៩ថា លោកស្រីខិតខំប្រឹងប្រែងក្នុងការគោរពសីលធម៌ទាំង១២ប្រការនេះ? លោកស្រីចាំទេថា លោកស្រីបានព្យាយាមគោរពតាមសីលធម៌ទាំង១២ប្រការនេះ តើមានអ៊ីចឹងទេ?

**ឆ៖** ចាស មានមែន តែមិនបានរាប់រៀបជាខ្សែចង្វាក់ទេ។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ ខ្ញុំនឹងជួយលោកស្រី។ តើលោកស្រីចាំសីលធម៌មួយណាក្នុងចំណោមសីលធម៌ទាំង១២នេះ ដែលនិយាយថា "កម្មាភិបាលគឺត្រូវធ្វើយ៉ាងម៉េចកុំឱ្យប៉ះពាល់ទៅដល់ស្ត្រី ឬក៏រំលោភទៅលើសិទ្ធិស្ត្រី"។ លោកស្រីមានចាំពីសីលធម៌មួយប្រការហ្នឹងទេ?

**ឆ៖** ចាសៗ ចាំ។

**ស៖** តើលោកស្រីចាំទេថា នៅពេលណាមួយនោះលោកស្រីបានអានសីលធម៌ទាំង១២ប្រការនេះនៅក្នុងទស្សនាវដ្តីមួយដែលមានឈ្មោះថា "ទង់បដិវត្ត"?

**ឆ៖** ខ្ញុំដូចមិនបានចាំ។ ធ្លាប់អានជាហូរហែ តែមិនបានចាំពេលណា។

[១៣:៣៩:៥៧]

**ស៖** តើលោកស្រីចាំទេថា -- ឧទាហរណ៍ដូចជាថាមានការចេញសេចក្តីណែនាំណាមួយពាក់ព័ន្ធទៅនឹងការបង្កើតគ្រួសារ ការកសាងគ្រួសារ ឬក៏ការរៀបអាពាហ៍ពិពាហ៍ លោកស្រីមានចាំអំពីគោល

នយោបាយពាកព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ ការបង្កើតគ្រួសារ ដែលវាៗមានទំនាក់ទំនងទៅនឹងសីលធម៌ទាំង១២ប្រការនេះ?

**ឆ៖** ខ្ញុំអត់យល់។

**ស៖** ខ្ញុំយល់ថាលោកស្រីមិនៗយល់ច្បាស់ ប្រហែលជាខ្ញុំសួរមិនត្រូវ ឥឡូវខ្ញុំសួរឡើងវិញ។ តើលោកស្រីដឹងទេថាបញ្ហាគ្រួសារ និងការរៀបអាពាហ៍ពិពាហ៍ គឺវាមានទំនាក់ទំនងទៅនឹងសីលធម៌ ទាំង១២ប្រការរបស់បដិវត្តដែលថាមិនត្រូវឲ្យរំលោភបំពានទៅលើស្ត្រីភេទនោះ?

**ឆ៖** ចាសៗ ខ្ញុំយល់។

**ស៖** ខ្ញុំអាចនិយាយអ៊ីចេះវិញ ការប្រព្រឹត្តចំពោះស្ត្រីហ្នឹង គឺវាពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់បក្ស ស្តីអំពីការកសាងគ្រួសារ។ តើពិតជាអ៊ីចឹងទេ?

**ឆ៖** ចាស។

**ស៖** តើត្រឹមត្រូវទេ ប្រសិនបើខ្ញុំនិយាយថាមានសីលធម៌ពីរ គឺមានៗគោលការណ៍ ឬសីលធម៌ពីរពាក់ព័ន្ធទៅនឹងគ្រួសារនិងការរៀបអាពាហ៍ពិពាហ៍។ គេថា -- ជាដំបូងគឺថាអ្នកទាំងពីរត្រូវព្រមព្រៀងគ្នា បន្ទាប់មកពេលដែលមានការព្រមព្រៀងគ្នារវាងសាមីខ្លួនទាំងពីរហើយ គឺគេធ្វើការរៀបអាពាហ៍ពិពាហ៍ហើយ តើត្រឹមត្រូវទេ?

[១៣:៤២:៥៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ បាទ សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំស្តាប់ឮសំណួររបស់មេធាវីការពារក្តី ខ្ញុំចោទសួរខ្លួនឯងពាក់ព័ន្ធនឹងសំណួរនេះ។ សាក្សីបាននិយាយថាគាត់ចាំថាមានសីលធម៌ទាំង១២ប្រការ ក៏ប៉ុន្តែគាត់អត់ចាំខ្លឹមសារពិតប្រាកដទេ ហើយសំណួរដែលសួរនេះគឺវា គឺសួរចង់បានចម្លើយគាត់ពាក់ព័ន្ធនឹងបញ្ហានេះ។ សំណួរហ្នឹងគឺយល់ -- សួរថា គឺមានសីលធម៌ពីរប្រការពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍និងគ្រួសារ ហើយខ្ញុំដូចមិនឮសាក្សីគាត់និយាយអំពីចំណុចទាំងពីរហ្នឹងទេ។ អ៊ីចឹងត្រូវសួរគាត់ជាៗបឋមសិន ថាតើគាត់ចាំខ្លឹមសារណាខ្លះនៃសីលធម៌ហ្នឹងទេ ហើយយើងមិនត្រូវឲ្យគាត់ -- ជំរុញឲ្យគាត់ធ្វើការសន្និដ្ឋាននូវអ្វីដែលគាត់បាននិយាយជាមុនទេ។ អ៊ីចឹងវិធីសាស្ត្រនេះគឺថាវាចោទជាបញ្ហាហើយលោកប្រធាន សូមអរគុណ។

[១៣:៤៤:១០]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំហាក់ដូចជាសួរទៅសាក្សីថាតើគាត់ចាំអំពីសីលធម៌ណាមួយក្នុងចំណោមសីលធម៌ទាំង១២ប្រការឬក៏អត់? ឧទាហរណ៍ ខ្ញុំសួរថាមានសីលធម៌មួយគេតែងនិយាយថាមិនត្រូវរំលោភសិទ្ធិស្ត្រី ហើយគាត់ឆ្លើយថាពិតជាបានចាំចំណុចហ្នឹងមែន អ៊ីចឹងហើយបានជាខ្ញុំសម្រេចចិត្តសួរសំណួរបន្ត ហើយៗអំមិញនេះខ្ញុំសួរសំណួរបែបហ្នឹងហើយ គឺថាវាសួរពាក់ព័ន្ធអំពីទំនាក់ទំនងរវាងសីលធម៌បដិវត្តន៍នេះទៅនឹងចំណុចដែលពាក់ព័ន្ធទៅនឹងការកសាងគ្រួសារ។ ដូច្នេះ ខ្ញុំសួរសំណួរច្បាស់លាស់ជាក់លាក់ហើយ ខ្ញុំគិតថាសាក្សីគាត់ប្រហែលជាអាចឆ្លើយនឹងសំណួររបស់ខ្ញុំបានដោយគ្មានបញ្ហាទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៥:៤៤]

**ប្រធានអង្គជំនុំ៖**

សូមមេធាវី វ៉ិចទ័រ កូប៉េ រៀបចំសំណួរចុងក្រោយរបស់លោក សួរចំពោះសាក្សីនេះ សាជាថ្មីម្តងទៀត។ សំណួររបស់លោកគឺវាទំនងជាឈានចូលទៅក្នុងកម្រិតនៃការប្រភេទសំណួរនាំមុខហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី គោលនយោបាយពាក់ព័ន្ធទៅនឹងការរៀបការ និងគ្រួសារ វាមានជាប់ពាក់ព័ន្ធទៅនឹងសីលធម៌ទី៦ ទេ គឺថា មិនត្រូវរំលោភលើសិទ្ធិស្ត្រី?

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស ខ្ញុំអត់យល់ចំណុចទី៦ នេះ អត់ចាំទាំងអស់ ភ្លេចអស់ហើយ។

**ស៖** ខ្ញុំនឹងរៀបចំសំណួរឡើងវិញ។ ខ្ញុំសួរសំណួរបែបផ្សេងវិញ។ គោលនយោបាយពាក់ព័ន្ធនឹងគ្រួសារ និងការរៀបអាពាហ៍ពិពាហ៍របស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹង គឺវាពាក់ព័ន្ធទៅនឹងគោលការណ៍ដែលថាភាគី សាមីខ្លួនត្រូវតែយល់ព្រមក្នុងការរៀបអាពាហ៍ពិពាហ៍ ហើយពេលដែលសាមីខ្លួនផ្អែក -- ព្រមព្រៀងហើយទើបនឹងមានការរៀបអាពាហ៍ពិពាហ៍។ តើ បើខ្ញុំនិយាយអ៊ីចឹងតើត្រឹមត្រូវទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** សំណួរចុងក្រោយពាក់ព័ន្ធនឹងបញ្ហានេះ គោលនយោបាយពាក់ព័ន្ធនឹងគ្រួសារ និងការរៀបអាពាហ៍ពិពាហ៍ ចេញវាចេញមកពីសីលធម៌បដិវត្តន៍ដែលបញ្ជាក់ថា មិនត្រូវប៉ះពាល់ទៅដល់ស្ត្រីភេទទេ

តើវាអ៊ីចឹងមែនទេ? លោកស្រីសាក្សី លោកស្រីស្តាប់ខ្ញុំសួរឮទេ?

[១៣:៤៩:១៣]

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចដែរលោកស្រី ខឹម បឿន? លោកស្រី ខឹម បឿន?

ដូចមានបញ្ហា សោតទស្សន៍ហើយ!

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

សួស្តី លោកស្រី ខឹម បឿន!

**លោកស្រី ខឹម បឿន៖**

ចាស លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ចាំស្តាប់សំណួរបន្តទៀត ស្តាប់សំណួរ ដើម្បីឆ្លើយតបនឹងសំណួរជាបន្តទៀត។

**លោកស្រី ខឹម បឿន៖**

ចាស។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកស្រីសាក្សី លោកស្រីស្តាប់ឮសំណួរខ្ញុំចុងក្រោយអម្បាញ់មិញនេះទេ ឬក៏លោកស្រីចង់ ឲ្យខ្ញុំសួរឡើងវិញ?

[១៣:៥១:០៤]

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាស សុំបញ្ជាក់សួរឡើងវិញ ព្រោះខ្ញុំស្តាប់អត់សូវបាន។ ហើយសំណួរជ្រៅពេកក៏ខ្ញុំស្តាប់មិនបានដែរ ព្រោះខ្ញុំមិនសូវចេះ។

**ស៖** ខ្ញុំនឹងព្យាយាមសួរឲ្យបានស្រួល។ គោលនយោបាយរបស់បក្សពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍ ផ្អែកទៅលើគោលការណ៍ពីរ គឺថាជាដំបូងសាមីខ្លួនត្រូវយល់ព្រមរៀបអាពាហ៍ពិពាហ៍ ហើយបន្ទាប់មក ពេលដែលព្រមព្រៀងគ្នាហើយគឺមានការរៀបអាពាហ៍ពិពាហ៍។ អ៊ីចឹងលោកស្រីអម្បាញ់មិញនេះ និយាយថាពិតជាអ៊ីចឹងហើយ។ អ៊ីចឹងខ្ញុំចង់ដឹងថាតើគោលការណ៍ទាំងពីរហ្នឹងវាកើត

ចេញមកពីសីលធម៌បដិវត្តន៍ដែលថា មិនត្រូវប្រព្រឹត្តអាក្រក់ ឬក៏ប្រព្រឹត្តមិនល្អ ចំពោះស្ត្រី។ តើវាអ៊ីចឹងមែនទេ?

**ឆៈ** ចាស អ៊ីចឹងមែន។

**សៈ** សូមអរគុណលោកស្រីសាក្សី។ ឥឡូវនេះ ខ្ញុំចូលទៅចំណុចផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងសីលធម៌ទាំង១២ប្រការនេះដដែល។ ខ្ញុំនឹងអានឃ្លាមួយនៃទស្សនាវដ្តីទង់បដិវត្តន៍នៅខែកក្កដា ឆ្នាំ១៩៧៨។ លោកប្រធាន ឯកសារគឺ E3/746, ERN ជាភាសាអង់គ្លេស 00428304 ទៅដល់ 05, ជាភាសាបារាំង 00611886, ជាភាសាខ្មែរ 00064504 ទៅដល់ 05។ លោកស្រីសាក្សី ខ្ញុំនឹងអានឃ្លាមួយនៃទស្សនាវដ្តីបដិវត្តពាក់ព័ន្ធទៅនឹងការជ្រើសរើសសមាជិកគណៈសហករណ៍។ គឺនិយាយអំពីចរិតលក្ខណៈរបស់អ្នកទាំងអស់នោះដើម្បីអាចក្លាយទៅជាសមាជិកគណៈកម្មការសហករណ៍ "ទី១ ត្រូវមានគោលជំហរបដិវត្តន៍រឹងប៉ឹង ខាងមាគ៌ានយោបាយរបស់បក្ស។ ទី២ ជំហរបដិវត្តន៍រឹងប៉ឹងខាងសតិ-អារម្មណ៍អធនរបស់បក្ស។ បន្ទាប់មកទៀត គឺអ្នកទាំងអស់ហ្នឹងត្រូវមានការប្រុងប្រយ័ត្នពាក់ព័ន្ធទៅនឹងអាកប្បកិរិយា គោលជំហរក្នុងការអនុវត្តភារកិច្ច គឺត្រូវប្រុងប្រយ័ត្នៗបំផុតគោលជំហរ និងអាកប្បកិរិយាធ្វើការងារបែបការិយាល័យនិយម នាហ្មឺននិយម អាជ្ញានិយម យោធានិយម សេរីនិយម ឯកចិត្តនិយម អត្តនោម័តិនិយម បែបមិនទទួលខុសត្រូវចំពោះបក្ស បដិវត្តន៍ និងប្រជាជន"។ លោកស្រីសាក្សីការណែនាំទៅដល់សមាជិកគណៈកម្មាធិការសហករណ៍នេះ ធ្វើឲ្យលោកស្រីមានចងចាំអ្វីឡើងវិញខ្លះទេ?

[១៣:៥៥:២៩]

**ឆៈ** ចាស ចងចាំខ្លះត្រង់ថា រើសអ្នកដឹកនាំសហករណ៍ គឺត្រូវរើសអ្នកដែលមានសីលធម៌ល្អ គោរពច្បាប់វិន័យរបស់បក្ស និងអត់ផ្តាត់ ដូចលោកមានប្រសាសន៍ គឺខ្ញុំឯកភាព។ ខ្ញុំមិនបានចាំហ្វូរហែទេ ខ្ញុំភ្លេចភ្លាំងអស់ហើយ។

**សៈ** ខ្ញុំយល់ថា ហេតុការណ៍នេះ វាកើតឡើងតាំងពីយូរណាស់មកហើយ ក៏ប៉ុន្តែលោកស្រីចាំទេថាមានសមាជិកគណៈសហករណ៍ណាដែលមិនមានលក្ខណៈសម្បត្តិបែបហ្នឹង ហើយដែលជាមនុស្សអាក្រក់ខាងបដិវត្ត។ លោកស្រីអាចផ្តល់ជាឧទាហរណ៍បានទេ?

**ឆៈ** ចាស សុំបញ្ជាក់ម្តងទៀត មិនច្បាស់ទេ។

**សៈ** តើលោកស្រីមានឧទាហរណ៍ថា កម្មាភិបាលណាមួយនៅក្នុងឃុំរបស់លោកស្រីដែលមាន

លក្ខណៈការិយាល័យនិយម នាហ្មឺននិយម អាជ្ញានិយម យោធានិយម សេរីនិយម ឯកចិត្តនិយមនេះ។ តើលោកស្រីគិតថា មានកម្មាភិបាលណាដែលប្រព្រឹត្តបែបហ្នឹងទេ នៅក្នុងឃុំរបស់លោកស្រីនោះ?

**ឆ៖** ចាស មិនមានដល់ច្រើនអីចឹងទេ មានគ្រាន់តែត្រឹមដូចខ្ញុំបានជម្រាប ការហួបចុកលាក់លៀមពីសមាជិក មិនទទួលខុសត្រូវ ហ្នឹងមាន ហៅថាដល់អាជ្ញានិយមអី មិនមានទេ។

**ស៖** ខ្ញុំនឹងចូលទៅដល់ឧទាហរណ៍ជាក់ស្តែង ជាឧទាហរណ៍ដែលយើងអាចរកឃើញនៅក្នុងសីលធម៌មួយក្នុងចំណោមសីលធម៌ទាំង១២ប្រការ។ គឺថាមិន -- ឧទាហរណ៍ថា មិនត្រូវផឹកស្រាទេក្នុងឋានៈជាកម្មាភិបាល។ តើលោកស្រីនៅចាំសីលធម៌មួយប្រការហ្នឹងទេ ដែលថាមិនត្រូវផឹកស្រាទេនៅក្នុងសម័យនោះ នៅក្នុងឃុំរបស់លោកស្រីនោះ?

**ឆ៖** ចាស ចាំ។

**ស៖** ប្រសិនបើគេចាប់បាន ថាកម្មាភិបាលណាម្នាក់កំពុងតែផឹកស្រានុ៎ង តើគេធ្វើយ៉ាងម៉េចចំពោះកម្មាភិបាលនោះ?

**ឆ៖** ចាស បើគេទៅទាន់កំពុងផឹក គេអាចហៅអប់រំ ព្រមានឲ្យថ្ងៃក្រោយកែប្រែ ហើយក៏ដកសិទ្ធិអត់ឲ្យនៅដឹកនាំក្នុងភូមិហ្នឹងទៀតទេ។

[១៣:៥៩:៤៨]

**ស៖** សូមអរគុណលោកស្រីសាក្សី។ ខ្ញុំចូលទៅប្រធានបទផ្សេងទៀត។ លោកប្រធានខ្ញុំត្រឡប់មកសំណួរដែលខ្ញុំសួរកាលពីមុនឈប់សម្រាក ខ្ញុំមិនដឹងថាតើអង្គជំនុំជម្រះបានសម្រេចទៅលើបញ្ហានេះហើយឬនៅ? អ្វីដែលខ្ញុំស្នើនោះគឺថា យ៉ាងហោចណាស់គឺមុនពេលអង្គជំនុំជម្រះសម្រេចនោះ គឺខ្ញុំអាចអាននូវឃ្លាមួយនៃចម្លើយសារភាពដើម្បីឲ្យអង្គជំនុំជម្រះដឹងថា តើខ្ញុំចង់និយាយអំពីអ្វី?

ខ្ញុំចង់ឲ្យអង្គជំនុំជម្រះដឹងអំពីអ្វីដែលខ្ញុំចង់លើកឡើងជូនទៅសាក្សីពាក់ព័ន្ធទៅនឹងចម្លើយសារភាពមួយ គឺប្រហែលជាមានប្រាំបី ទៅ១០បន្ទាត់ ដែលខ្ញុំចង់អានជូនអង្គជំនុំជម្រះ។ បន្ទាប់មក យើងខ្ញុំនឹងស្តាប់ការសម្រេចរបស់អង្គជំនុំជម្រះ--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីព្រឹកមិញ មិនអនុញ្ញាតឲ្យប្រើប្រាស់នូវខ្លឹមសារដែលបានមកពីការធ្វើទារុណកម្មមកដាក់សួរដេញដោលសាក្សីទេ។ ចំណែកឯសេចក្តីសម្រេចពេញលេញនោះ អង្គជំនុំជម្រះបានជម្រាបហើយថានឹងចេញនូវសប្តាហ៍ក្រោយ។ ព្រឹកមិញដូចបានជម្រាបរួចហើយ

ក្រោយពិភាក្សាគ្នាសម្រេចច្បាស់លាស់ហើយ។ មិនត្រឹមតែប៉ុណ្ណោះទេ ព្រឹកមិញលោកតវ៉ាថា សហព្រះរាជអាជ្ញារងអន្តរជាតិហ្នឹងបានលើកផ្នែកណាមួយមកសួរបានផង។ ដូច្នេះច្បាស់លាស់ហើយ យើងបានសម្រេចរួចហើយមិនអនុញ្ញាតឲ្យធ្វើដូច្នេះទេ។ ហើយមានសំណួរអ្វីផ្សេងទៀត សូមអញ្ជើញ!

[១៤:០១:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមអភ័យទោសដែលខ្ញុំយល់ច្រឡំ ខ្ញុំ -- ដោយសារខ្ញុំគិតថាមិនទាន់មានការសម្រេចផ្លូវការនៅឡើយ។ ដូច្នេះឥឡូវនេះខ្ញុំសូមបន្តទៅទៀត។ ខ្ញុំឃើញថាសាក្សីមិនទាន់បានឆ្លើយទេ ប៉ុន្តែខ្ញុំចង់បង្ហាញជាកំណត់ត្រា គឺថាខ្ញុំចង់បញ្ជាក់ជាកំណត់ត្រាថា ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យអាន។ ដូច្នេះ ខ្ញុំចង់ឲ្យដឹងថាតើអ្វីដែលខ្ញុំចង់សួរទៅសាក្សីហ្នឹង ដូច្នេះខ្ញុំនឹងសួរសំណួរទេ ប៉ុន្តែដើម្បីជាកំណត់ត្រា។ ប៉ុន្តែយ៉ាងណាក៏ដោយអង្គជំនុំជម្រះបានសម្រេចមិនឲ្យខ្ញុំសួរសាក្សី ដូច្នេះខ្ញុំចង់ឲ្យមានការកត់ត្រានៅក្នុងកំណត់ត្រាដើម្បីឲ្យខ្ញុំអាចផ្តិតប្តឹងសាទុក្ខបានទៅលើសាក្សី។ ហើយចង់បញ្ជាក់ថា ខ្ញុំចង់សួរសំណួរប្រភេទនេះទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ មិនមានប្រយោជន៍អ្វីក្នុងការអានឃ្លានៃឯកសារមួយដែលមិនត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យសួរសំណួរនេះទេ នេះជាចំណុចទី១។ ចំណុចទី២ នេះគឺជាប៉ុនប៉ងមួយនៅពេលដែលគាត់ចង់អានឃ្លាមួយ ដើម្បីជះឥទ្ធិពលទៅលើសាក្សីសម្រាប់សំណួរផ្សេងៗទៀតខាងមុខ។ អ៊ីចឹង ខ្ញុំគិតថាចំណុចនេះច្បាស់ហើយ អ៊ីចឹងធ្វើម៉េចអង្គជំនុំជម្រះសូមកុំឲ្យធ្លាក់ក្នុងអន្ទាក់របស់មេធាវីការពារក្តី ហើយសូមធ្វើយ៉ាងម៉េចកុំឲ្យឯកភាពទៅតាមសំណើរបស់មេធាវីការពារក្តី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឡើយ សូម្បីតែអានផ្នែកណាមួយក៏ដោយនៃខ្លឹមសារកំណត់ហេតុដែលបានមកពីការធ្វើទារុណកម្ម! ចប់!

[១៤:០៣:៥២]

**លោក វ៉ិចទ័រ កូប៉េះ**

នេះជាការសម្រេចដ៏គួរឲ្យចាប់អារម្មណ៍មែនទែនលោកប្រធាន។ ប៉ុន្តែយ៉ាងណាក៏ដោយយើងនៅសល់មន្ទីរស-២១ នៅពេលខាងមុខទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** អត់បញ្ហាទេ លោកស្រីសាក្សី ខ្ញុំនឹងបន្តទៅផ្នែកចុងក្រោយបំផុតនៃការសួររបស់ខ្ញុំ គឺនិយាយអំពីស្វាមីរបស់លោកស្រីនៅក្នុងឃុំពពេល។ អ្វីដែលខ្ញុំចង់សួរ គឺថាគេសួរពីរបីដងរួចមកហើយ គឺថាវាត្រូវបាន -- ដូច្នេះ ខ្ញុំចង់សួរថាតើលោកស្រីធ្លាប់ពិភាក្សាជាមួយស្វាមីរបស់លោកស្រីអំពីការងារនៅក្នុងឃុំរបស់លោកស្រីអំពីការសម្រេចចិត្តរបស់លោកស្រី ហើយតើប្តីរបស់លោកស្រីធ្លាប់ជជែកអំពីការងាររបស់គាត់នៅក្នុងឃុំ អំពីការសម្រេចចិត្ត អំពីគោលនយោបាយរបស់គាត់ដែរឬទេ?

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ខ្ញុំអត់ច្បាស់ទេ សូមម្តងទៀត។

**ស៖** និយាយដោយសង្ខេប តើលោកស្រីធ្លាប់ជជែកជាមួយប្តីលោកស្រីក្នុងចន្លោះឆ្នាំ៧៥ដល់៧៩ អំពីការងាររបស់លោកស្រីដែរឬទេ? តើលោកស្រី ហើយនិងប្តីធ្លាប់ជជែកពីរឿងការងារដែរឬទេ?

**ឆ៖** ចាស ការ -- ប្តីប្រពន្ធមានការជជែក មានការខ្វែងយោបល់គ្នាជាធម្មតា មិនមែនបានន័យថាជាការឈ្លោះប្រកែកដែលធំដុំទៅលើប្រការមួយផ្សេង ដូចជានយោបាយក៏ដោយ ផ្ទាល់ខ្លួនក៏ដោយ គឺមានៗការជជែក មាននេះគ្នាចាស។

[១៤:០៥:០២]

**ស៖** តើអាចនិយាយបានថា ការសម្រេចចិត្តរបស់ប្តីលោកស្រី គោលនយោបាយរបស់ប្តីលោកស្រីនៅឃុំពពេល គឺដូចគ្នា ឬក៏វាប្រហាក់ប្រហែលគ្នានឹងការសម្រេចរបស់លោកស្រី ឬក៏គោលនយោ-បាយរបស់លោកស្រីក្នុងឃុំរបស់លោកស្រីដែរឬទេ?

**ឆ៖** ការណ៍នេះខ្ញុំវិនិច្ឆ័យមិនបាន ហើយក៏ក្តាប់មិនបានដែរ។ ដូចថាផែនការដាក់ពីលើមកម៉េចគឺធ្វើអ៊ីចឹងដូចគ្នា។

**ស៖** ប៉ុន្តែនៅពេលអនុវត្តគោលនយោបាយហ្នឹង ថាតើការអនុវត្តរបស់លោកស្រី ហើយនិងការអនុវត្តរបស់ប្តីលោកស្រីដូចគ្នា ឬក៏ខុសគ្នា?

**ឆ៖** ខ្ញុំមិនបានដឹងច្បាស់ដែរ ព្រោះការងារដោយឡែកពីគ្នា។ ការប្រាស្រ័យទាក់ទងក៏អត់សួរ

ដែលបានជួបគ្នាដែរ ជួនកាលមួយខែមិនទាន់ជួបម្តងក៏មាន ជួបតែពេលការងារ។ ដូច្នេះ អត់មានបានប្រាស្រ័យទាក់ទងទេ។

**ស៖** អរគុណលោកស្រី ប្រធានបទចុងក្រោយដែលខ្ញុំចង់ពិភាក្សាជាមួយលោកស្រីនៅពេលនេះ គឺស្ថានភាពខ្មាំង ឬក៏ស្ថានភាពការពារប្រទេសនៅក្នុងខែមេសា ឧសភា មិថុនា ឆ្នាំ៧៧ គឺពីរឆ្នាំក្រោយពេលរំដោះ។ តើលោកស្រីចាំទេ ថាមានការកើនឡើងនូវអំពើហិង្សាមកពីខាងប្រទេសវៀតណាមនៅក្នុងខែមេសា ឧសភា មិថុនា ឆ្នាំ៧៧ដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់បានចាំទេ ព្រោះ៧៧នេះខ្ញុំឈឺពេញមួយឆ្នាំ។

**ស៖** ដូច្នេះលោកស្រីមិនអាចឆ្លើយអំពីស្ថានភាពខ្មាំង សកម្មភាពខ្មាំងនៅតាមព្រំដែននៅក្នុងអំឡុង -- នៅក្នុងបណ្តាខែនាឆ្នាំ៧៧ទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស។

**ស៖** សូមអរគុណលោកស្រីសាក្សីដែលបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំ។ បាទ សូមអរគុណ។

[១៤:០៩:២៦]

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកស្រីសាក្សី ខ្ញុំបាទ គង់ សំអុន ជាមេធាវីជាតិរបស់លោក ខៀវ សំផន។ ហើយតទៅនេះខ្ញុំមានសំណួរមួយចំនួនដើម្បីសុំការបំភ្លឺពីលោកស្រី។ ទាក់ទងទៅនឹងសក្ខីកម្មរបស់អ្នកស្រី គឺកំណត់នៃការស្តាប់ចម្លើយសាក្សីរបស់អ្នកស្រីដែលមានលេខ E312 – E312/12.3.2 ត្រង់សំណួរចម្លើយ ១៧, ១៨ និង១៩។ លោកស្រីបានឆ្លើយទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយក៏បានឆ្លើយពីម្សិលមិញផងដែរទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញារងជាតិក្នុងប្រហែលម៉ោង០៩:៣០ នាទីព្រឹក។ លោកស្រីបានឆ្លើយបញ្ជាក់ថា លោកស្រីមិនដែលស្គាល់លោក ខៀវ សំផន ទេ ហើយមិនដែលជួបលោក ខៀវ សំផនទេ និងក៏មិនដែលធ្វើជានីរសារឲ្យលោក ខៀវ សំផនដែរ។ សំណួររបស់ខ្ញុំចង់សួរ

អ្នកស្រីថា តើអ្នកស្រីធ្លាប់ធ្វើជានីរសារទេក្នុងការងារកន្លងមក អាចថាពីឆ្នាំ៧០ រហូតមកដល់៧៩ ក្តី?

**ឆ៖** ចាស អត់ទេ ខ្ញុំមានកូនតូចតាច មានធ្វើនីរសារកើតទេ។

**ប្រធានអង្គជំនុំ៖**

មេធាវីដូចជាទំនងច្រឡំលេខឯកសារដឹង តាមទំនងជា 319 មិនមែន 312 ទេ។

**លោក គង់ សំអុន៖**

ខ្ញុំសូមបញ្ជាក់បន្តិចលោកប្រធាន។ បាទសូមអធ្យាស្រ័យលោកប្រធានគឺ E319/12.3.2។

**សួរដោយ លោក គង់ សំអុន៖**

**ស៖** បាទ សំណួរតទៅទៀតទាក់ទងនឹងឯកសារនេះដដែល ត្រង់សំណួរចម្លើយលេខ៣២៧។ ខ្ញុំសូមអានជូន ដកស្រង់៖ “នៅក្នុងអំឡុងពេលបីឆ្នាំនៃរបបខ្មែរក្រហម តើធ្លាប់មានកម្មាភិបាល (ខៀវ សំផន, ប៉ុល ពត, នួន ជា) ជាន់ខ្ពស់ណាទៅទស្សនកិច្ចតំបន់របស់លោកស្រីដែរឬទេ?” អ្នកស្រីបានឆ្លើយថា ឆ្លើយ៣២៧៖ “អត់មានទេ គឺមានតែតាម៉ុក ប៉ុណ្ណោះ ម៉្យាងវិញទៀតគ្មានអ្នកណាស្គាល់ខៀវ សំផន, ប៉ុល ពត ឬក៏ នួន ជា នោះទេ”។ សំណួររបស់ខ្ញុំៗចង់សួរថា តើអ្នកស្រីនៅៗយល់ស្របតាមសក្ខីកម្មរបស់អ្នកស្រីនេះទេ?

**ឆ៖** ចាស ខ្ញុំនៅរក្សាសិទ្ធិដដែល។

[១៤:១៤:១៥]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងតាម៉ុក ហើយនិងគ្រួសាររបស់គាត់ អ្នកស្រីបានឆ្លើយនៅក្នុងឯកសារកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រីដដែលហ្នឹង ត្រង់សំណួរ-ចម្លើយលេខ២០-- សូមទោសលេខ ៥៥ និង ៥៦។ អ្នកស្រីបានឆ្លើយថា នៅពេលដែលសួរ ខ្ញុំសូមដកស្រង់សំណួរសិន៖ “តើលោកស្រីស្គាល់តាម៉ុកដែរឬទេ? ឆ្លើយលេខ៥៥៖ ចាស ខ្ញុំស្គាល់។ តាម៉ុក ជាអ្នកដើរមើលការងារតាមសហករណ៍និងតាមឃុំ។ សួរ៖ តើលោកស្រីស្គាល់ តាម៉ុក ដោយផ្ទាល់ដែរឬទេ? ឆ្លើយ៥៦៖ ចាស ខ្ញុំស្គាល់គាត់ផ្ទាល់។ មានពេលខ្លះគាត់ចុះមកមើលកន្លែងបាយនៅតាមសហករណ៍ គាត់បានសួរប្រជាជនអំពីការហូបចុកឆ្អែតដែរឬទេ។ តាម៉ុក ចុះមើលគ្រប់កន្លែងទាំងអស់។ ខ្ញុំធ្លាប់ជួបតាម៉ុក”។ ខ្ញុំចង់សួរបញ្ជាក់ថា តើអ្នកស្រីនៅទទួលស្គាល់ថាសក្ខីកម្មរបស់អ្នកស្រីនេះត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមទៀតថាតើលោកស្រីដឹងថា តាម៉ុក គាត់បាន

ធ្វើដំណើរនៅតាមតំបន់នានាដទៃទៀតដែរឬទេ?

**ឆៈ** ចាស ខ្ញុំអត់ដឹងទេ។ ដឹងតែត្រឹមនៅក្នុងភូមិស្រុករបស់ខ្ញុំ។

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសំណួរនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រី គឺសំណួរ-ចម្លើយលេខ៦១ អ្នកស្រីបានឆ្លើយថា សូមដកស្រង់៖ "ប្រហែលជាមួយឆ្នាំមុនវត់យួន ខ្ញុំលែងឃើញ តាម៉ុក ទៀតហើយ ដោយគាត់ទៅធ្វើការនៅកន្លែងផ្សេង តែខ្ញុំមិនដឹងនៅកន្លែងណាទេ"។ ខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីនៅរក្សាសក្ខីកម្មរបស់អ្នកស្រីនេះទេ?

**ឆៈ** ចាស។

**សៈ** បាទ សូមអរគុណ។ ខ្ញុំចង់សួរថា តើអ្នកស្រីធ្លាប់ឮពាក្យមួយឃ្លាថា "នៅលើ ម៉ុក មានមួក ហើយនៅលើមួកមានមេឃ"។ អ្នកស្រីធ្លាប់ដែលឮប្រយោគហ្នឹងទេ ពីមុនមក?

**ឆៈ** ចាស អត់ៗដែលឮ។

[១៤:១៧:៥៥]

**សៈ** បាទ សូមអរគុណ។ ទាក់ទងទៅនឹងតួនាទី មុខងាររបស់អ្នកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកស្រីបានបញ្ជាក់កន្លងរួចមកហើយថា អ្នកស្រីធ្លាប់ធ្វើជាប្រធានឃុំ នៅក្នុងដំណាក់កាលដំបូង។ ហើយក្រោយមកជិតពេលបញ្ចប់ទៅហើយ អ្នកស្រីបានធ្វើនៅថ្នាក់ស្រុក។ អ៊ីចឹងជាដំបូង ខ្ញុំចង់សួរបញ្ជាក់សំណួរមួយចំនួន ទៅលើការងាររបស់អ្នកស្រីទាក់ទងទៅនឹងថ្នាក់ឃុំ។ លោកស្រីបានមានប្រសាសន៍ថាលោកស្រីបានចូលរួមប្រជុំថ្នាក់តំបន់គឺតំបន់១៣ នៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតសួរអ្នកស្រី គឺត្រង់សំណួរ-ចម្លើយលេខ៨២ ខ្ញុំសូមដកស្រង់ជូន៖ "ក្នុងការប្រជុំនៅមន្ទីរតំបន់១៣ តើមានកម្មាភិបាលជាន់ខ្ពស់ដែលមកពីមជ្ឈិមនៅភ្នំពេញធ្លាប់ចូលរួមប្រជុំដែរឬទេ? ចម្លើយរបស់អ្នកស្រី លេខ៨២៖ អត់ដែលមានកម្មាភិបាលមកពីមជ្ឈិមចូលរួមប្រជុំនោះទេ"។ សូមចប់ការដកស្រង់។ តើអ្នកស្រីនៅប្រកាន់នូវសក្ខីកម្មរបស់អ្នកស្រីថាត្រឹមត្រូវដែរឬទេ?

**ឆៈ** ចាស ត្រឹមត្រូវ។

**សៈ** បាទសូមអរគុណ។ អ្នកស្រីមានដែលឃើញ តាម៉ុក ចូលរួមប្រជុំនៅក្នុងថ្នាក់តំបន់ហ្នឹងដែរទេ?

**ឆៈ** ចាស ធ្លាប់ឃើញដែរ។

[១៤:២០:១០]

**ស៖** បាទ សូមអរគុណ។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់អ្នកស្រីដដែលគឺត្រង់ សំណួរ-ចម្លើយលេខ៨៥។ សំណួរសួរថា សូមដកស្រង់៖ "តើលទ្ធផលនៃកិច្ចប្រជុំត្រូវបានលើកយកទៅផ្សព្វផ្សាយនៅថ្នាក់មជ្ឈិមដែរឬទេ? អ្នកស្រីបានឆ្លើយត្រង់ចម្លើយ៨៥ថា៖ ខ្ញុំមិនដឹងថាគេរាយការណ៍ ទៅមជ្ឈិមឬអត់នោះទេ"។ សូមបិទការដកស្រង់។ តើអ្នកស្រីនៅប្រកាន់នូវសក្ខីកម្មរបស់អ្នកស្រីនេះថាត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** បាទ ទាក់ទងទៅនឹងសំណួរចម្លើយលេខ១៨០ -- សុំទោស លេខ១៤៦ នៃសក្ខីកម្មរបស់អ្នកស្រីដដែល។ សូមដកស្រង់ចម្លើយលេខ១៤៦៖ "គឺបញ្ជូនទៅថ្នាក់ស្រុក ហើយខ្ញុំមិនដឹងថា ថ្នាក់ស្រុកបញ្ជូនទៅថ្នាក់លើទៀតឬអត់នោះទេ"។ អ្នកស្រីនៅប្រកាន់សក្ខីកម្មរបស់អ្នកស្រីនេះថាត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** បាទ ទាក់ទងទៅនឹងបញ្ហាកសិកម្ម ដែលមានការពិភាក្សាយ៉ាងច្រើននៅក្នុងតុលាការនេះកន្លងមកគឺទាក់ទងទៅនឹងការផលិតឲ្យបាន៣តោនក្នុង១ហិកតា។ តើអ្នកស្រីបានដឹងពីនយោបាយនៃការផលិតស្រូវ៣តោនក្នុង១ហិកតានេះពីកន្លែងណាមកដែរ? ហើយដឹងពីអ្នកណា? អ្នកស្រីអាចបញ្ជាក់បានទេ?

[១៤:២២:៣០]

**ឆ៖** ចាស ខ្ញុំអាចចាំបានខ្លះតែមិនពិតប្រាកដ ខ្ញុំនិយាយទៅវាមានលើសខ្វះ។ ការទទួលផែនការដែលផលិតស្រូវក្នុង១ហិកតា បាន៣តោន នេះគឺខ្ញុំបានទទួលការណែនាំពីស្រុកឲ្យចុះធ្វើស្រែ ដាក់ជីរឲ្យបានច្រើន ធ្វើ១ហិកតា ឲ្យបាន៣តោន។

**ស៖** លោកចាំថា អ្នកណានៅថ្នាក់ស្រុកដែលបានប្រជុំប្រាប់លោកស្រីទេ?

**ឆ៖** ខ្ញុំចង់ភ្លេច។ ជំនាន់តាចាយ ជំនាន់តាគិត យូរហើយ។

**ស៖** បាទ សូមអរគុណ ខ្ញុំសូមបន្តសំណួរទៀត។ ទាក់ទងទៅនឹងការប្រជុំបន្ទាន់ នៅពេលការិយាល័យសហព្រះរាជអាជ្ញាសួរអ្នកស្រីទាក់ទងទៅនឹងសំណួរ-ចម្លើយលេខ១៦០។ អ្នកស្រីបានឆ្លើយថា ខ្ញុំសូមដកស្រង់៖ "ប្រជុំបន្ទាន់មានច្រើនយ៉ាង ឧទាហរណ៍ថានៅក្នុងឃុំខ្ញុំមានស្រូវអង្ករលើស ហើយឃុំណាដែលខ្វះនោះគេហៅខ្ញុំទៅភ្លាម ដើម្បីចែករំលែកយកស្រូវអង្ករដែលលើសនោះទៅឲ្យកន្លែងដែលខ្វះខាត"។ សូមបិទការដកស្រង់។ ក្នុងចំណុចនេះ ខ្ញុំចង់សួរអ្នកស្រីថា តើឃុំរបស់អ្នកស្រីមានស្រូវអង្ករ

លើសច្រើនដែរទេ?

**ឆ៖** ចាស លើសមិនច្រើនទេ តែបើប្រៀបធៀបទៅឃុំផ្សេងៗ គឺឃុំខ្ញុំគេយកចេញរហូតរាល់ឆ្នាំ ដឹកស្រូវចេញពីឃុំខ្ញុំទៅឧបត្ថម្ភផ្សេងៗ។

[១៤:២៤:៤២]

**ស៖** បាទ សូមអរគុណ ខ្ញុំសូមបន្តសំណួរទៀត។ ទាក់ទងកំណត់ហេតុរបស់អ្នកស្រីដដែលត្រង់សំណួរចម្លើយលេខ៨៣។ អ្នកស្រីបានឆ្លើយថា សូមដកស្រង់៖ "នៅក្នុងមូលដ្ឋាន នៅក្នុងភូមិឃុំមានព្រឹត្តិការណ៍អ្វីកើតឡើង ឬក៏មានសភាពការអ្វីកើតឡើង ភូមិរាយការណ៍ឲ្យខ្ញុំ ហើយបើខ្ញុំមិនអាចដោះស្រាយបាន ខ្ញុំត្រូវបញ្ជូនទៅខាងលើទៀត។ ក្រៅពីនេះ គឺមានតែនិយាយអំពីការខ្វះអាហារហូបចុកនៅតាមសហករណ៍ ហើយយើងត្រូវធ្វើដំណាំរួមផ្សំផ្សេងទៀត ដើម្បីហូបចុក។ ម្យ៉ាងវិញទៀត បើមានអ្នកណាខិលខូច យើងត្រូវរាយការណ៍ និងបញ្ជូនអ្នកទាំងអស់នោះទៅខាងលើ តែខ្ញុំមិនសូវបានបញ្ជូននោះទេ"។ ខ្ញុំសួរបញ្ជាក់ថា តើអ្នកស្រីនៅប្រកាន់ថានេះជាសក្ខីកម្មរបស់អ្នកស្រីត្រឹមត្រូវដែរទេ?

**ឆ៖** ចាស។

**ស៖** តើអ្នកស្រីអាចបញ្ជាក់ថាមានបញ្ហាខ្លះដែលអ្នកស្រីធ្វើការសម្រេចដោយខ្លួនឯង អ៊ីចឹងដែរទេ?

**ឆ៖** គ្មានទេ។

**ស៖** បាទ ខ្ញុំចង់បញ្ជាក់ទៅលើចំណុចនេះម្តងទៀត ក្រែងអ្នកស្រីមិនអាចស្តាប់ខ្ញុំយល់។ ក្នុងចម្លើយ៨៣របស់អ្នកស្រីនេះ អ្នកស្រីនិយាយអំពីការរៀបការទៅថ្នាក់លើទៀត ហើយកិច្ចការមួយចំនួននោះអ្នកស្រីដោះស្រាយដោយខ្លួនឯង។ អ៊ីចឹងសំណួររបស់ខ្ញុំ ខ្ញុំសួរអ្នកស្រីថា វាមានការងារខ្លះដែលអ្នកស្រីធ្វើដោយសម្រេចចិត្តដោយខ្លួនឯង មិនមែនថាគ្រប់ការងារទាំងអស់ អ្នកស្រីត្រូវតែរាយការណ៍ទៅថ្នាក់លើនោះទេ។ អ្នកស្រីស្តាប់ខ្ញុំបានទេ?

**ឆ៖** ចាស។

**ស៖** ហើយខ្ញុំនិយាយអ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** ចាស។

[១៤:២៧:២៦]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការងាររបស់អ្នកស្រីនៅថ្នាក់ស្រុកវិញ នៅក្នុងឯកសារ

ដដែល កំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រី។ នៅក្នុងសំណួរចម្លើយលេខ២៧៥, ២៧៦ និង២៧៧។ ខ្ញុំសូមដកស្រង់ ចម្លើយរបស់អ្នកស្រីត្រង់លេខ២៧៥។ សូមដកស្រង់៖ "តារ៉ន ជាអ្នកតែងតាំងខ្ញុំជាគណៈស្រុក។ គាត់ពុំបានតែងតាំងអ្វីនោះទេ គាត់គ្រាន់តែប្រាប់ខ្ញុំថាឲ្យទៅជួយធ្វើការងារស្រុក ព្រោះសាន គាត់ធ្វើតែម្នាក់។ ម្យ៉ាងទៀត ម្យ៉ាងវិញទៀត ដើម្បីទៅជួយមើលនារីកាត់ដេរស្រុកផង។ ពុំមានលិខិតជាលាយលក្ខណ៍អក្សរនោះទេ ឧទាហរណ៍ថា ពេលដែលមានប្រជុំ គេប្រាប់យើងថា ពួកឯងត្រូវធ្វើនេះ អ្នកឯងត្រូវផ្លាស់ប្តូរពីនេះទៅនោះ។ តារ៉ន និយាយថា ទៅជួយ សាន ផង ព្រោះ សាន ម្នាក់ឯង។ តារ៉ន ប្រហែលជាទទួលបញ្ជាពីថ្នាក់លើដែរ។ សួរ៖ ថ្នាក់តំបន់មកប្រាប់លោកស្រីឲ្យធ្វើជាគណៈស្រុក ហើយតំបន់ប្រហែលជាទទួលបញ្ជាពីលើ តើលោកស្រីគិតថា សេចក្តីសម្រេចដែលតែងតាំងលោកស្រីជាគណៈស្រុក អាចចេញពីមជ្ឈិមនៅភ្នំពេញដែរឬទេ? ចម្លើយលេខ២៧៦៖ អត់ទេ គឺចេញពីតំបន់។ សួរ៖ តើថ្នាក់តំបន់អាចធ្វើការតែងតាំងអ្នកធ្វើការថ្នាក់ស្រុក ដោយមិនពិភាក្សាជាមួយនឹងភូមិភាគដែរឬទេ? ចម្លើយ២៧៧៖ ខ្ញុំមិនដឹងទេ"។ សូមបិទការដកស្រង់។ ខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីនៅគាំទ្រសក្ខីកម្មរបស់អ្នកស្រីនេះថាជាសក្ខីកម្មត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

[១៤:៣០:១៨]

**ស៖** បាទសូមអរគុណ។ លោកស្រីបានឆ្លើយជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ក៏ដូចជានៅក្នុងពេលសវនាការពេលម្សិលមិញនេះផងដែរ ទាក់ទងទៅនឹងការតែងតាំងអ្នកស្រីនៅស្រុកត្រាំកក់នេះ ជាគណៈកម្មការស្រុកត្រាំកក់នេះ ថាអ្នកស្រីត្រូវបានតែងតាំងនៅក្នុងខែតុលា ឆ្នាំ១៩៧៨។ គឺមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រីក្នុងសំណួរចម្លើយលេខ៣០និង៣១។ ដែលទាក់ទងទៅនឹងការបង្កើតច្បាប់មួយហៅច្បាប់លើកលែង។ អ្នកស្រីអាចពន្យល់បានបន្ថែមទេ ពីពាក្យថា "ច្បាប់លើកលែង" នេះមានន័យយ៉ាងម៉េចនៅក្នុងសំណួរចម្លើយលេខ៣០ និង៣១នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រី?

**ឆ៖** ចាស ខ្ញុំមិនបានចាំច្បាស់ទេ គ្រាន់ថាមានច្បាប់លើកលែងអ្នកដែលមានទោសកំហុសតិចតួចអី គឺលើកលែង ដោះស្រាយឲ្យលែងទាំងអស់។ នេះដែលខ្ញុំចាំ ក្រៅពីនោះខ្ញុំចាំមិនបានទេ។

**ស៖** បាទ អ្នកស្រីបញ្ជាក់អំពីការលែងទាំងអស់អំមិញ និយាយ -- តើមានន័យថាជាការលើកលែងឈប់ឲ្យមានការចោទប្រកាន់ ចាប់ទោសកំហុសអី ឬមួយយ៉ាងម៉េច អ្នកស្រីអាចបញ្ជាក់បានទេ?

**ផ៖** ខ្ញុំយល់តែខ្លឹមសារថា ខ្លឹមសារលើកលែងៗបានន័យថា លើកលែងទោសកំហុសដែលអ្នកធ្វើខុសឆ្គងតិចតួច ឬក៏កម្រិតណាក៏ខ្ញុំមិនយល់ដែរ ខ្ញុំយល់ត្រឹមថា ច្បាប់លើកលែងប៉ុណ្ណោះឯង។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់បានទេថា អ្នកស្រីនៅស្រុកត្រាំកក់នោះរហូតដល់ពេលណាដែរ? ពីព្រោះអ្នកស្រីបានបញ្ជាក់ថា អ្នកស្រីត្រូវបានតែងតាំងក្នុងខែតុលា ឆ្នាំ១៩៧៨។ ចុះអ្នកស្រីនៅរហូតដល់ពេលណាបានចេញពីស្រុកត្រាំកក់?

**ផ៖** ចាស ខ្ញុំនៅដល់ពេលដែលវៀតណាមចូលស្រុក គឺរត់ទៅព្រៃតែម្តង។

**ស៖** អ្នកស្រីចាំកាលបរិច្ឆេទទេ ឬមួយក៏អ្នកស្រីអាចធ្វើការប្រៀបធៀបថា អ្នកស្រីចាកចេញមុនថ្ងៃ៧ មករា ៧៩ អាចមុន ឬក្នុងរយៈពេលប៉ុន្មានដែរ? អ្នកស្រីអាចធ្វើការប្រៀបធៀបពីកាលបរិច្ឆេទនេះបានទេ?

**ផ៖** ខ្ញុំមិនចាំទេ តែខ្ញុំចេញក្នុងពេលដែលយន្តហោះទម្លាក់នៅទីក្រុងតាកែវ ថ្ងៃនោះឯងដែលថ្ងៃខ្ញុំចេញពេលល្ងាច តែខ្ញុំអត់បានចាំថ្ងៃខែទេ។

[១៤:៣៤:០៤]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសំណួរចម្លើយលេខ៦៩ នៅក្នុងសក្ខីកម្មរបស់អ្នកស្រីដដែល ខ្ញុំសូមដកស្រង់៖ "សំណួរ៖ តើលោកស្រីទៅមន្ទីរតំបន់១៣ ក្នុងពេលលោកស្រីជាមេឃុំ ឬក៏ពេលលោកស្រីធ្វើជាគណៈស្រុក? ចម្លើយ៦៩៖ គឺនៅពេលដែលខ្ញុំធ្វើជាមេឃុំ។ ចំណែកពេលដែលខ្ញុំធ្វើគណៈស្រុក គឺមិនដែលទៅប្រជុំទេ ព្រោះវៀតណាមជិតវ៉ៃចូលដល់ ហើយមានភាពចលាចល គឺពុំបានទៅប្រជុំទេ"។ បិទការដកស្រង់។ ខ្ញុំចង់សួរអ្នកស្រីថា តើអ្នកស្រីនៅប្រកាន់នូវសក្ខីកម្មរបស់អ្នកស្រីនេះថាត្រឹមត្រូវដែរទេ?

**ផ៖** ចាស។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមបន្តសំណួរទាក់ទងទៅនឹងទង់បដិវត្ត។ នៅក្នុងកំណត់ហេតុរបស់អ្នកស្រីដដែល ត្រង់សំណួរ-ចម្លើយលេខ១២១ បាទសំណួរសូមដកស្រង់៖ "ក្នុងនាមជាមេឃុំ តើលោកស្រីធ្លាប់ឃោសនាអំពីខ្លឹមសារទស្សនាវដ្តីទង់បដិវត្តពីរប្រភេទ ដែលបានចេញផ្សាយនៅពេលនោះដែរឬទេ? ចម្លើយលេខ១២១៖ ខ្ញុំមិនដឹងថា មានទស្សនាវដ្តីនោះទេ ក្រែងតែថ្នាក់លើមានទស្សនាវដ្តីយ៉ាងម៉េចខ្ញុំមិនដឹងទេ តែថ្នាក់ខ្ញុំមិនមានទេ"។ ចប់ការដកស្រង់។ តើអ្នកស្រីនៅប្រកាន់ថាសក្ខីកម្មរបស់អ្នកស្រីនេះត្រឹមត្រូវដែរឬទេ?

[១៤:៣៦:៣៥]

**ឆ៖** ចាស ខ្ញុំអត់ដឹងមែនកាលនោះ។

**ស៖** បាទ សូមអរគុណ។ ចុះនៅពេលដែលអ្នកស្រីនៅថ្នាក់ស្រុក ជាគណៈកម្មការស្រុក តើអ្នកស្រីបានឃើញទស្សនាវដ្ដីទង់បដិវត្តទាំងនោះទេ?

**ឆ៖** ចាស ឃើញតែមិនបានចាំខ្លឹមសារទេ។

**ស៖** អ្នកស្រីថា "ឃើញ" មានន័យថា អ្នកស្រីបានអាន ឬក៏គ្រាន់តែឃើញទស្សនាវដ្ដី?

**ឆ៖** ចាស ពេលវេលាខ្ញុំវាមមាញឹក ខ្ញុំមិនបានអានហ្មត់ចត់ទេ គ្រាន់តែឃើញអានបានតិចតួចនាយអាយ ព្រោះពេលនោះរវល់ គឺរវល់ប្រមូលផលពេលនោះ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមចូលទៅប្រធានបទមួយទៀតទាក់ទងទៅនឹងអាពាហ៍ពិពាហ៍។ ម្សិលមិញម៉ោងប្រហែលប្រាំបួនហាសិបប្រាំនាទីព្រឹក អ្នកស្រីបានមានប្រសាសន៍អំពីអាពិហ៍ពិពាហ៍ដែលទាក់ទងទៅនឹងបញ្ហាដែលអាចនាំឲ្យមានកំហុសសីលធម៌ ការប្រព្រឹត្តនូវកំហុសសីលធម៌។ ខ្ញុំចង់សួរអ្នកស្រីថា តើមានករណីដែលបុរសនិងស្ត្រីដែលៗនៅលីវ អាចរួមភេទដោយស្ម័គ្រចិត្តបានទេក្នុងពេលនោះ? បានន័យថា គាត់អាចស្រឡាញ់គ្នាដោយមិនមានការរៀបការជាមុន។

**ឆ៖** ចាស អត់មានទេ អត់បានទេ។

[១៤:៣៩:១៣]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសំណួរចម្លើយលេខ១៥៣ និង១៥៤ នៅក្នុងសក្ខីកម្មរបស់អ្នកស្រីដដែល។ ខ្ញុំសូមដកស្រង់ចម្លើយ១៥៣ សូមដកស្រង់៖ "ចំពោះកន្លែងរបស់ខ្ញុំ បើមានករណីនេះកើតឡើង គឺមានន័យថាបុរសនិងស្ត្រីនោះស្រឡាញ់គ្នា។ ដូច្នេះ ភូមិនឹងត្រូវគេរាយការណ៍មកខ្ញុំ ហើយខ្ញុំហៅពួកគេមកនិយាយជាមួយ រួចនឹងរៀបការឲ្យតែម្ដង។ សួរ៖ តើគេចាត់ទុកថាអំពើនេះជាបទល្មើសដែរឬទេ? ចម្លើយលេខ១៥៤៖ ចាស ជាអំពើខុសនឹងប្រពៃណី"។ សូមបិទការដកស្រង់។ តើអ្នកស្រីនៅប្រកាន់ថាជាចម្លើយត្រឹមត្រូវរបស់អ្នកស្រីដែរទេ អ្វីដែលខ្ញុំបានអានជូនអម្បាញ់មិញនេះ?

**ឆ៖** អត់ច្បាស់ សូមបន្តិចទៀត។

**ស៖** បាទ សូមអរគុណ។ ខ្ញុំៗនឹងអានជូនសាជាថ្មី។ ទាក់ទងទៅនឹងសំណួរចម្លើយលេខ១៥៣ និងលេខ១៥៤។ នៅក្នុងចម្លើយលេខ១៥៣ ខ្ញុំសូមអានជូន សូមដកស្រង់៖ "ចំពោះកន្លែងរបស់ខ្ញុំ បើមានករណីនេះកើតឡើង គឺមានន័យថាបុរស និងស្ត្រីនោះស្រឡាញ់គ្នា ដូច្នេះ ភូមិនឹងត្រូវគេរាយការណ៍

មកខ្ញុំ ហើយខ្ញុំហៅពួកគេមកនិយាយជាមួយ រួចនឹងរៀបការឲ្យតែម្តង។ សួរ៖ តើគេចាត់ទុកថាអំពើនេះជាបទល្មើសដែរឬទេ? ចម្លើយលេខ១៥៤៖ ចាស ជាអំពើខុសនឹងប្រពៃណី"។ សូមចប់ការដកស្រង់។ ពាក្យថា "អំពើ"នេះហ្នឹង គឺបានន័យថាជាការរួមភេទរវាងបុរសនិងស្ត្រីដែលនៅលីវ ហើយដែលបានស្រឡាញ់គ្នាដោយស្ម័គ្រចិត្ត។ អ៊ីចឹង អ្នកស្រីនៅប្រកាន់ថាសក្ខីកម្មរបស់អ្នកស្រីនេះត្រឹមត្រូវដែរទេ?

**ផ៖** ចាស ខ្ញុំសូមសាឡើងវិញ ខ្ញុំអត់ៗៗទាន់ត្រូវទេ ព្រោះអីបានសាមីខ្លួនទាំងសងខាងបានសារភាព ហើយក៏ភូមិ និងឃុំបានឯកភាពគ្នារៀបចំឲ្យហើយ នេះអត់មានអីខុសទេ។ ចាស ខ្ញុំឆ្លើយមុនខុស។

[១៤:៤២:១៣]

**ស៖** បាទ អ៊ីចឹងខ្ញុំសូមបញ្ជាក់សក្ខីកម្មរបស់អ្នកស្រីឡើងវិញថា បើសិនជាបុរស និងស្ត្រីដែលនៅលីវ ហើយស្រឡាញ់គ្នា ហើយបានមកសារភាពថាគេស្រឡាញ់គ្នា អ៊ីចឹងអាហ្នឹងអត់មែនជាកំហុសសីលធម៌ទេ បានន័យថាគេអាចរៀបការជាមួយគ្នាបាន អ្នកស្រីនិយាយអ៊ីចឹងមែនទេ?

**ផ៖** ចាស។

**ស៖** បាទ--

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីដល់ពេលសម្រាកហើយ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ លោកស្រី ខឹម បឿន ឥឡូវនេះដល់ពេលសម្រាកហើយ ៗសវនាការនឹងបន្តធ្វើរហូតដល់ --ចាប់ពីម៉ោងបីទៅ សូមលោកៗស្រីអាចសម្រាកបានហើយរួមទាំងមេធាវីប្រឹក្សា ហើយនិងអញ្ជើញមកកាន់កន្លែងផ្តល់សក្ខីកម្មនៅកន្លែងដែលលោកស្រីអង្គុយផ្តល់សក្ខីកម្មនោះ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ លោកស្រីសាក្សី លោកស្រីស្តាប់ខ្ញុំឮទេឥឡូវនេះ។

**លោកស្រី ខឹម បឿន៖**

**ឆ៖** ចាសឮ។

**ស៖** បាទ មុនសម្រាកអំមិញយើងពិភាក្សាគ្នាអំពីការរៀបអាពាហ៍ពិពាហ៍ ហើយតទៅនេះ ខ្ញុំលើកសំណួរទាក់ទងទៅនឹងសំណួរ-ចម្លើយរបស់អ្នកស្រី គឺសំណួរ-ចម្លើយលេខ១៥៦ នៃសក្ខីកម្មរបស់អ្នកស្រី គឺកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រី។ ខ្ញុំសូមដកស្រង់៖ "សួរ៖ តើត្រូវមានការយល់ព្រមពីឪពុកម្តាយ ឬពីអង្គការ? ចម្លើយ១៥៦៖ ត្រូវមានការយល់ព្រមពីឪពុកម្តាយ ហើយនិងក៏ត្រូវរាយការណ៍ទៅអង្គការ គឺរាយការណ៍ទៅថ្នាក់ស្រុក"។ បាទ សូមបិទការដកស្រង់។ ទាក់ទងចំណុចនេះ គឺទាក់ទងទៅនឹងការសម្រេច អនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកស្រីថា តើលោកស្រីនៅប្រកាន់សក្ខីកម្មរបស់អ្នកស្រីថាត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

[១៥:០៣:៤៩]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងសំណួរចម្លើយលេខ១១៣ ខ្ញុំសូមដកស្រង់៖ "តើការរៀបការដោយបង្ខំនេះ ឬការកំណត់ឲ្យរៀបការនេះ ថ្នាក់មជ្ឈិមកំណត់មកថ្នាក់ភូមិភាគ ហើយមកថ្នាក់តំបន់ រួចមកហើយថ្នាក់ស្រុកឃុំតែម្តង ឬក៏ការរៀបការនេះ គឺថ្នាក់ឃុំស្រុកជាអ្នកសម្រេច? ចម្លើយ១១៣៖ ការរៀបការនេះ គឺមិនមានថ្នាក់មជ្ឈិមអ្វីទេ គឺថ្នាក់ឃុំ ស្រុក ជាអ្នករៀបចំ"។ សូមបិទការដកស្រង់។ សំណួរ ខ្ញុំសូមសួរអ្នកស្រីថា តើអ្នកស្រីនៅប្រកាន់ជំហរ ថាសក្ខីកម្មរបស់អ្នកស្រីត្រឹមត្រូវដែរទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការសម្រេចឲ្យរៀបការ សាក្សីម្នាក់ឈ្មោះ ពេជ្រ ជឹម ដែលគាត់មកផ្តល់សក្ខីកម្មប៉ុន្មានថ្ងៃមុននេះ គឺនៅថ្ងៃទី២២ ខែ៤ ឆ្នាំ២០១៥ ដែលមានលេខឯកសារ E1/290.1 នៅម៉ោងប្រហែល១៣:៥៧ នាទី។ ខ្ញុំសូមដកស្រង់៖ "សំណួរ៖ ហើយសេចក្តីសម្រេច

រៀបការជាក្រុម តើជាសេចក្ដីសម្រេចរបស់ថ្នាក់ស្រុកផ្ទាល់ ឬមួយក៏ជាការបង្គាប់បញ្ជាពីថ្នាក់លើ? ឆ្លើយ៖ ពី១លើ គ្រាន់តែយល់ព្រមឲ្យធ្វើ ធ្វើយ៉ាងម៉េចក៏បានទៅ ជាក្រុមក៏បាន ជារាយក៏បាន ស្រេចយើងពិគ្រោះគ្នាទេ ស្រេចយើងពិគ្រោះទេ។ ឃុំនិងស្រុកពិគ្រោះទៅ ធ្វើដំណើរគ្នាទៅ ធ្វើទៅ ប៉ុនសួមសួរម៉ែឪគេផង បងប្អូនគេផង ហើយសំខាន់សាមីខ្លួន គេព្រម មិនព្រម"។ សូមចប់ការដកស្រង់។

សំណួររបស់ខ្ញុំ សួរថា តើអ្នកស្រីយល់ស្របតាមសក្ខីកម្មរបស់លោក ពេជ្រ ជឹម នេះទេ?

**ផ៖** ចាស ខ្ញុំយល់ស្រប។

[១៥:០៧:១៨]

**ស៖** បាទ សូមអរគុណ។ សូមចូលប្រធានបទថ្មី ទាក់ទងទៅនឹងមន្ទីរក្រាំងតាចាន់។ នៅពេលដែលស្ដាប់ចម្លើយរបស់អ្នកស្រីដោយការិយាល័យសហចៅក្រមស៊ើបអង្កេត អ្នកស្រីបានមានប្រសាសន៍អំពីមន្ទីរក្រាំងតាចាន់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ស្រុក នៅក្នុងសក្ខីកម្មរបស់អ្នកស្រីដដែលត្រង់សំណួរចម្លើយលេខ១៨៧។ តើអ្នកស្រីបញ្ជាក់ថាសក្ខីកម្មរបស់អ្នកស្រី ដែលឆ្លើយថាមន្ទីរក្រាំងតាចាន់ នៅក្រោមការគ្រប់គ្រងរបស់ស្រុកនេះត្រឹមត្រូវដែរឬទេ?

**ផ៖** ចាស ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ ម្សិលមិញម៉ោងប្រហែល ១១:០៨ នាទី ការិយាល័យសហព្រះរាជអាជ្ញា បានបង្ហាញឯកសារមួយដែលជាសំបុត្រពី តាអាន់ ដែលជាប្រធានក្រាំងតាចាន់ ផ្ញើមកលោកស្រីដែលមានចុះថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៧៧ ដែលមានលេខឯកសារ E3/2012។ នៅក្នុងឯកសារនោះ តាអាន់ បានស្នើលោកស្រីឲ្យបញ្ជូនឈ្លបទៅចាប់មនុស្សពីរនាក់។ ហើយការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្ហាញឯកសារនោះទៅអ្នកស្រីផងដែរ ហើយអ្នកស្រីបានឆ្លើយថាឃុំរបស់អ្នកស្រីបានទទួលឯកសារប្រភេទនោះដែរ គឺឯកសារ E សូមទោស គឺឯកសារដែលខ្ញុំបានជម្រាបជូនអម្បាញ់មិញនេះ E3/2012។ អ្នកស្រីរកឯកសារហ្នឹងឃើញទេ ឯកសារ E3/2012?

**ផ៖** អត់។

[១៥:១០:៥៥]

**ស៖** ម៉េចហើយលោកស្រីរកឃើញហើយនៅ?

**ផ៖** នៅ។

**លោក ម៉ម រិទ្ធា៖**

សូមគោរពលោកប្រធាន តើខ្ញុំអាចបង្ហាញយកឯកសារហ្នឹងជូនទៅសាក្សីមើលបានទេ? ព្រោះសាក្សី -- ឯកសារអត់នៅក្នុងដៃខ្ញុំនៅឡើយទេ ប៉ុន្តែនៅខាងមន្ត្រីទុកឯកសារ?

**ប្រធានអង្គជំនុំ៖**

បាទ បាន១ អង្គជំនុំជម្រះអនុញ្ញាត គ្រាន់តែសម្របសម្រួលការងារផ្តល់ឯកសារ។ អាហ្នឹងចង្អុលបង្ហាញគាត់ផង ដើម្បីឲ្យគាត់ងាយឆាប់ស្គាល់ ឆាប់ដល់ទីកន្លែងដែលមានបំណងសាកសួររបស់មេធាវីការពារក្តី។

**លោក ម៉ម រិទ្ធា៖**

បាទ សូមអរគុណលោកប្រធាន។

**លោកស្រី ខឹម ហឿន៖**

មេធាវីអានជូនផងបានទេ? ព្រោះខ្ញុំមើលអត់ឃើញ។

[១៥:១១:៥៦]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ លោកស្រីអាចសង្ខេបសាច់រឿងដែលមានក្នុងលិខិតហ្នឹង។ គឺជាលិខិតមួយដែលផ្ញើតាអាន់ ជាអ្នកផ្ញើមកលោកស្រី ហើយឲ្យអ្នកស្រីបញ្ជូនឈ្លបទៅចាប់មនុស្សពីរនាក់។ អ្នកស្រីចាំសាច់រឿងទេ? សហព្រះរាជអាជ្ញាបានសួរករណីហ្នឹងរួចហើយ។

**លោកស្រី ខឹម ហឿន៖**

**ឆ៖** ខ្ញុំដូចអត់បានចាំ។

**ស៖** អ្នកស្រីអាចមើលឯកសារហ្នឹងឃើញ ហើយអាចចងចាំបានពីឯកសារហ្នឹងទេ ថាអ្នកស្រីបានទទួលឯកសារហ្នឹងនៅក្នុងឃុំរបស់អ្នកស្រីកាលពីរបបកម្ពុជាប្រជាធិបតេយ្យនោះ? ឯកសារដែលបានចុះថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៧៧។

**ឆ៖** ខ្ញុំមិនបានចាំច្បាស់ទេ លោកប្រធាន។ តែឈ្មោះ អាន់ នេះ ដឹងតើនៅកន្លែងក្រាំងតាចាន់ហើយ។

[១៥:១៣:៣៦]

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងចំណុចនេះ ខ្ញុំចាំបានចម្លើយរបស់អ្នកស្រី ជាសំណួរ

ចុងក្រោយរបស់លោកមេធាវី កូប៉េ នៅរសៀលនេះ។ អ្នកស្រីបានឆ្លើយថា អ្នកស្រីឈឺនៅក្នុងឆ្នាំ១៩៧៧ គឺឈឺពេញមួយឆ្នាំ។ អ្នកស្រីអាចបញ្ជាក់បានទេ ថានៅពេលអ្នកស្រីឈឺនោះ អ្នកស្រីទៅធ្វើការដែរទេ?

**ផ៖** ចាស ពេលដែលខ្ញុំឈឺ ខ្ញុំមានជំងឺផង ខ្ញុំមានផ្ទៃពោះផង។ ដូច្នេះ ខ្ញុំអត់បានដើរទៅធ្វើការឆ្ងាយទេ គឺខ្ញុំនៅកន្លែង និងនៅផ្ទះ ផ្ទះរបស់ខ្ញុំ។ ខ្លះនៅកន្លែងខ្លះ នៅកន្លែងធ្វើការងារ។ ដូច្នេះ ការបញ្ជូនការងារអីក៏វាមានច្រើនដែរ ភាគច្រើនខាងយោធា គឺខ្ញុំអត់សូវបានទទួលបានទេ ការផ្ញើសំបុត្រ។ មានឈ្មោះខ្ញុំក៏ពិតមែន តែការគ្រប់គ្រងខាងល្បាបខាងអីគឺខាងបុរស។ ខ្ញុំអត់បានជាប់ចិតថេរដិតដល់ទេចាស។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងលិខិតនេះ ខ្ញុំចង់ឲ្យអ្នកស្រីបញ្ជាក់ឲ្យបានច្បាស់ថា អ្នកស្រីនៅក្នុងឃុំរបស់អ្នកស្រីហ្នឹងបានទទួលលិខិតបែបនេះទេ ឬក៏អ្នកស្រីមិនដឹង មិនអាចធ្វើការបញ្ជាក់បាន? សូមអ្នកស្រីជួយឆ្លើយ?

**ផ៖** ចាស ខ្ញុំមិនលាក់លៀមអីទេ ប៉ុន្តែខ្ញុំដូចជាអត់បានទទួល នឹកមិនឃើញ។

**ស៖** បាទ សូមអរគុណ។ បាទ ទាក់ទងទៅនឹងការងារនៅថ្នាក់តំបន់ អ្នកស្រីបានលើកនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រីនៅក្នុងសំណួរ-ចម្លើយលេខ៥៩ ថា សំ ប៊ិត ជាគណៈកម្មការតំបន់ គឺតំបន់១៣ ក្នុងមួយរយៈពេល ហើយបន្ទាប់មកឈ្មោះ រ៉ន មកធ្វើជាគណៈកម្មការតំបន់១៣ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។

នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស្រីត្រង់ចម្លើយលេខ៥៩ ខ្ញុំសូមដកស្រង់៖ "ចាស បន្ទាប់មកទៀត សំ ប៊ិត ដែលកាន់ខាងកងទ័ពបានមកគ្រប់គ្រងតំបន់១៣ ហើយខ្ញុំមិនដឹង សំ ប៊ិត មកពីកងទ័ពណាទេ។ សំ ប៊ិត ធ្វើជាគណៈតំបន់១៣ បានមួយរយៈ តែមិនរហូតដល់ចប់របបខ្មែរក្រហមនោះទេ។ ក្រោយមកទៀត ឈ្មោះ រ៉ន (ប្រុស) ធ្វើជាគណៈតំបន់១៣ រហូតដល់ចប់របបខ្មែរក្រហម។ ខ្ញុំមិនចាំឈ្មោះពេញរបស់ រ៉ន ទេ"។ សូមចប់ការដកស្រង់។ សំណួររបស់ខ្ញុំ សូមសួរអ្នកស្រីថា តើលោកស្រីស្គាល់ សំ ប៊ិត និង តារ៉ន ថាមានទំនាក់ទំនងអ្វីជាមួយ តាម៉ុក ដែរទេ? ជាសាច់ញាតិរបស់ តាម៉ុក ដែរទេ? អ្នកស្រីមានដឹងទេ?

**ផ៖** ចាស ខ្ញុំអត់បានដឹងទេ។ ខ្ញុំអត់សូវស្គាល់ផង។

[១៥:១៨:៤៥]

**ស៖** បាទ សូមអរគុណ។ ចុះអ្នកស្រីស្គាល់ថានរណាជាប្រធានតំបន់១៣ មុន សំ ប៊ិត? អ្នកស្រីស្គាល់ទេ?

**ធ៖** មិនដឹងអ្នកណា ច្រើន។ ផ្លាស់ប្តូរច្រើនពេក ខ្ញុំមិនចាំបន្ទាប់ពី សំ ប៊ិត ហ្នឹងដែរ។

**ស៖** បាទ មុន មិនមែនខ្ញុំសួរពី សំ ប៊ិត ទេ គឺខ្ញុំសួរអំពីគណៈតំបន់ ដែលកាន់តំបន់១៣ មុនសំប៊ិត។ អ្នកស្រីចាំឈ្មោះអីទេ?

**ធ៖** មានតែឈ្មោះ សោម និង មុត ហ្នឹង ស្គាល់តែពីរនាក់ហ្នឹង។

**ស៖** បាទ សូមអរគុណ។ ព្រឹកមិញនេះ អ្នកស្រីឆ្លើយនឹងសំណួររបស់លោកចៅក្រម ឡាវែន៍ អ្នកស្រីបញ្ជាក់ពីឈ្មោះ ប្រាក់ ដែលធ្លាប់ធ្វើការនៅតំបន់។ អ្នកស្រីស្គាល់ថាឈ្មោះ ប្រាក់ ហ្នឹងមានតួនាទីនៅក្នុងតំបន់១៣ហ្នឹង ក្នុងគណៈកម្មាធិការតំបន់១៣ហ្នឹង?

**ធ៖** ចាស សូមទោស ខ្ញុំច្រឡំ វង្វេងវង្វាន់។ ចាស បន្ទាប់មកមុន សំ ប៊ិត ហ្នឹងគឺឈ្មោះ ប្រាក់ ហ្នឹង តែមិនដឹងថាត្រកូលអីទេ គាត់តួនាទីជាគណៈតំបន់១៣ តែក្នុងរយៈពេលខ្លីទេ។

**ស៖** បាទ អ្នកស្រីអាចចាំថារយៈពេលប៉ុន្មានខ្លីហ្នឹង ជាខែ ឬក៏ជាឆ្នាំ?

**ធ៖** ខ្ញុំដូចចាំមិនច្បាស់ទេ មិនដឹងជាដល់ឆ្នាំ ឬក៏មិនដល់។ ប៉ុនខ្ញុំថាអាចមិនលើសពីមួយឆ្នាំទេ។

[១៥:២១:១៨]

**ស៖** បាទ អ៊ីចឹងអ្នកស្រីចាំបានថា សំ ប៊ិត មកជំនួសឈ្មោះ ប្រាក់ ហ្នឹងនៅពេលណាដែរទេ?

**ធ៖** ខ្ញុំអត់បានចាំទេលោក។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងឯកសារ E3/2048។ ឯកសារនេះបានបង្ហាញរួចហើយ លោកស្រីរកឃើញឯកសារហ្នឹងទេ ឥឡូវហ្នឹង?

**ធ៖** ចាស កំពុងតែមើល។

**ស៖** ម៉េចទៅអ្នកស្រី រកឃើញហើយនៅ?

**ធ៖** ឃើញហើយ ប៉ុន្តែមើលមិនទាន់ច្បាស់ មើលមិនសូវឃើញ។

**ស៖** បាទ អត់អីទេ អ្នកស្រីចាំបន្តិចសិនទៅ។ ឯកសារមួយទៀត គឺឯកសារដែលមានលេខ D157.64 ដែលលោកចៅក្រម ឡាវែន៍ បានសួរមុននេះដែរ លោកស្រីជួយរកផងទៅ ខ្ញុំនឹងមានសំណួរទាក់ទងនឹងឯកសារទាំងពីរនេះ។

[១៥:២៤:២៣]

**ស៖** លោកស្រីរកឃើញឯកសារហ្នឹងហើយនៅ? ឯកសារចុងក្រោយ?

**ធ៖** ចាស ឃើញហើយ។

**ស៖** បាទ ឯកសារនេះខ្លីទេ ហើយខ្ញុំសូមឲ្យលោកស្រីពិនិត្យមើលខាងក្រោមនៃៗឯកសារហ្នឹង។ ឯកសារហ្នឹងគឺជា "សេចក្ដីរាយការណ៍" ចំណងជើងរបស់ឯកសារ ហើយខាងក្រោមមានសរសេរឈ្មោះលោកស្រី –ឈ្មោះ ហឿន– ទាំងពីរឯកសារហ្នឹង។ សំណួររបស់ខ្ញុំៗសួរលោកស្រីថា តើឈ្មោះ ហឿន នេះ ជាៗឈ្មោះ ឬក៏ជាហត្ថលេខារបស់លោកស្រី? លោកស្រីអាចបញ្ជាក់បានទេ? ទាំងពីរឯកសារហ្នឹង ដែលមានឈ្មោះហឿនហ្នឹង។ ហឿន ហ្នឹងជាហត្ថលេខា ឬក៏ជាឈ្មោះ?

**ឆ៖** នេះជាឈ្មោះ មិនមែនជាហត្ថលេខាទេ។

**ស៖** បាទសូមអរគុណ។ ចុះអ្នកស្រីប្រើហត្ថលេខាផ្សេងពីនេះ អ៊ីចឹងមែនទេ?

**ឆ៖** ចាស មានឈ្មោះ មានស៊ីញ៉េថែមបញ្ជាក់។ នេះអត់មានតែឈ្មោះ។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់បានទេពីអក្សរនេះ អ្នកស្រីស្គាល់ទេថាជាអក្សររបស់អ្នកណា?

**ឆ៖** ខ្ញុំមិនស្គាល់ទេៗ។

[១៥:២៦:៣៣]

**ស៖** បាទ សូមអរគុណ។ តើលោកស្រីអាចបញ្ជាក់ទេ ថាវាជាអក្សររបស់អ្នកស្រី ឬក៏ជាអក្សររបស់អ្នកផ្សេង?

**ឆ៖** មិនមែនជាអក្សររបស់ខ្ញុំទេ ហើយក៏អត់មាននាមត្រកូល អត់មានអី ឈ្មោះទទេ។

**ស៖** បាទ សូមអរគុណលោកស្រី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកបន្តទៅធ្វើនៅថ្ងៃព្រហស្បតិ៍ ទី០៧ ខែឧសភា ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃព្រហស្បតិ៍ ទី០៧ ខែឧសភា អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-222 -- 822 បាទ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់នេះ។

អង្គជំនុំជម្រះសូមអរគុណលោកស្រី ខឹម ហឿន ដែលបានចំណាយពេលវេលាដ៏មានតម្លៃផ្ដល់សក្ខីកម្មតាមរយៈសោតទស្សន៍ ក្នុងឋានៈជាសាក្សី ក្នុងរយៈពេលពីរថ្ងៃកន្លងមកនេះ។ សក្ខីកម្មរបស់

លោកស្រីនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិត ក្នុងរឿងក្ដីនេះ។ ហើយការផ្ដល់សក្ខីកម្មរបស់លោកស្រីបានដល់ទីបញ្ចប់ហើយ លោកស្រីអាចសម្រាកបានហើយ។ សូមលោកស្រីមានសុខភាពល្អ ហើយទទួលបានសេចក្ដីសុខ សេចក្ដីចម្រើន។

ហើយអង្គជំនុំជម្រះសូមអរគុណផងដែរ ចំពោះមេធាវី ម៉ម រិទ្ធា ជាមេធាវីប្រឹក្សាសាក្សី ដល់ពេលនេះលោកអាចសម្រាកបានហើយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបមកត្រឡប់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី០៧ ខែឧសភា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:២៨ នាទី)*